## វគ្គទី៨

## ល្បិច ថ្មីបន្ថែមលើគម្រោងការចាស់

ធាតុអាកាសប្រែទៅជាអាប់អួ...ប្រហែលចូលរួមហ្មងចិត្តជាមួយស្រីស្អាតមេក្រុមបង្ហាញម៉ូតដែលខកខានលែងបានត្រឡប់ទៅរកមាតុប្រទេសតាមចិត្តចងនោះដែរហើយ។

រសៀលឈានចូលសាជាថ្មី ដោយនាំមកនូវទិដ្ឋភាពរុក្ខជាតិស្វិតស្រពោនស្មើរប្រដូចទៅនឹងរដូវប្រាំងទោះបីខ្យល់រងនៅតែបបោសអង្អែលសត្វលោកលើដែនកោះនាឆ្នេរស៊ូម៉ាត្រា។

នៅក្នុងបន្ទប់សម្រាកលំដាប់កំពូលមួយ នារីម្នាក់មាឌខ្ពស់ស្តើង ប្រកបដោយឆោមលោមពណ៌សម្បុរស្បែក និងការតុបតែងបែបស៊ីវិល័យដើរចុះឡើងចច្រប់ហាក់កំពុងគិតគូរពីរឿងអ្វីមួយដោយអន្ទះសា។ ក្នុងផ្ទៃបន្ទប់ព្ធសូរតែស្នូរកែងចោតរបស់នាងដែលបញ្ជាក់ពីភាពស្វាហាប់ និងឆ្លៀវឆ្លាត។ នាងគឺនារីស្រស់ស្អាតទី២របស់កន្និរីហ្វេស្សិនដែលកេតឌីម៉ាគិតថាកំពុងរងទុក្ខដោយការចាប់ជំរិតនោះ។

-លំអង! ឈប់ដើរទៅមកទៅ! បងកំពុងស្មុគស្មាញណាស់!

លំអងក្នុងទឹកមុខអន្ទះសាងាកមករកKenជាសង្សារវិញ ខណៈដែលបុរសនោះបន្លឺសម្តីបែបមិនពេញចិត្តៈ

-ស្រីល្ងង់នោះ វាដល់ថ្នាក់សូម្បីកន្លែងនោះឈ្មោះអីក៏មិនចាំ ឲ្យយើងទៅរកនៅឯណាទៅបើតណ្ឌូណេស៊ីធំម្លឹងៗ?

Kenនិយាយចប់ដកដង្ហើមយូរលើកកែវស្រាមកក្រេប។ នារីស៊ីវិល័យបញ្ឈប់ជំហានហើយបន្លឺម្តងមួយៗមកបន្ធូរភាពស្មុគស្មាញបន្តៈ

-ក៏គ្រាន់ដែរ ដែលវាចេះបានព័ត៌មានខ្លះៗមក! សុទ្ធតែជាព័ត៌មានសំខាន់!

Kenរក្សាកែវស្រាក្បែរបបូរមាត់ទោះគេលែងក្រេបហើយក៏ដោយ។ គេរវេ្ភកវិះគិតខណៈសំឡេងលំអងបន្តលាន់ឮមកៈ

-ហោចណាស់យើងដឹងវាមនរិន្ទមកតណ្ឌូណេស៊ីលើកនេះគឺមកពីរកឃើញតម្រុយទាក់ទងនឹងបដិមានោះមែន! ហើយវត្ថុដែលបងKenចង់បានសឹងមួយជីវិតមកហើយនេះ គឺនៅតណ្ឌូណេស៊ីនេះ!សរសើរដែរ ថ្នាំដេកលក់មួយកូនដបសោះ អាចជួយយើងច្រើនម្លឹងៗ។

ដំបូងប្រុសស្រីល្បិចជ្រៅទាំងពីរគ្រាន់តែមានចេតនាអូសបន្លាយពេលកេតឌីម៉ានៅទីនេះដើម្បីតាមដានរាមនរិន្ទតែប៉ុណ្ណោះ ព្រោះតាំងពីដើមមកគេបានទុកបុរសមកពីត្រកូលអ្នកនយោបាយជាគោលដៅ ដោយមធ្យោបាយបណ្តោយឲ្យរាមនរិន្ទតាមរកឃើញវត្ថុបុរាណនោះ ជាមុនរួចទើបគេជាអ្នកទទួលផលសម្រេចចុងក្រោយ។ ប៉ុន្តែពេលនេះអ្វីៗហាក់វិវឌ្ឍន៍លឿនជ្រុល ដោយគ្មាននរណានឹកដល់ទេថាវត្ថុបុរាណដែលនៅសេសសល់តែពាក្យដំណាលបន្ទាប់ពីការរសាត់អណ្តែតអស់រាប់ពាន់ឆ្នាំនោះ ឥឡូវលេចពន្លឺមកវិញសឹងមិនគួរឲ្យជឿ។

លំអង និងKenទទួលស្គាល់ថា ការដែលពួកគេឱបដៃបណ្តោយឲ្យរាមនរិន្ទជាអ្នកពុះពារស្វែងរកឥន្ទប្បដិមា នរាធិបតិន្ទគឺជាការគិតត្រូវ១០០%ដោយសារថារាមនរិន្ទមានឥទ្ធិពល និងមានអំណាចអាចសម្រួលការងារនេះសម្រេចរហ័សជាងអ្នកឯទៀត។

Kenនិយាយមួយក្នុងពេលកំពុងសញ្ជឹងគិត៖

-លំអង! បងយល់ថាផែនការយើងត្រូវដូរបន្តិច! ពីមុនយើងឲ្យរកវិធីបន្តកេតឌីម៉ាឲ្យនៅជាមួយរាមនរិន្ទមួយគ្រា គ្រាន់តែដើម្បីស៊ើបការណ៍ថាវាមកឥណ្ឌូណេស៊ីធ្វើអីតែឥឡូវ...

លំអងបញ្ចប់ប្រយោគប្រុសស្នេហ៍៖

-ឥឡូវយើងត្រូវប្រាកដថា នាងល្ងង់នោះត្រូវនៅជាមួយរាមនរិន្ទរហូតដល់ ឥន្ទប្បដិមា នរាធិបតិន្ទធ្លាក់មកក្នុងដៃយើង!

Kenងក់ក្បាលផ្ងក់ៗនៅពេលស្រីស្នេហ៍បញ្ចេញយោបល់ស្របអ្វីដែលខ្លួនកំពុងគិត។ ប៉ុន្តែគេងាកសួរស្រីស្នេហ៍វិញ៖

-ប៉ុន្តែកេតឌីម៉ាព្រមនៅតែប៉ុន្មានថ្ងៃទៀតដោយសារបារម្ភពីអូនត្រូវគេចាប់ទេ! មានវិធីអីឲ្យស្រីល្ងង់ហ្នឹងព្រមនៅជាមួយរាមនរិន្ទយូរទៀតនោះ?

លំអងមិនទាន់ឆ្លើយថាយ៉ាងណាផង ស្នូរគោះទ្វារលាន់ឡើង។ នាយKenក្រោកទៅពិនិត្យតាមប្រឡោះទ្វាររួចទើបបើកអោយចូល។ គេដើរបកត្រឡប់មកក្នុងវិញដោយមានមនុស្សក្រោមបង្គាប់ពីរនាក់ដើរត្រុនៗចូលមកតាមពីក្រោយ។ Kenនិយាយសួរដោយមិនមើលមុខ៖

-ម៉េចហើយ? ស៊ើបដឹងទេអាឡុង?

បុរសធាត់ក្រអាញសម្បុរស្រអែមដែលទើបបង្ហាញខ្លួនឆ្លើយតបដោយស្វាហាប់៖

-ជើងយន្តហោះដែលចេញពីបាលីទៅទាំងអស់ គឺចុះនៅហ្សាកាតាសិនមុនពេលចេញទៅណាបន្ត! ចំណែកតំបន់ដែលចំណាយពេលសរុប១យប់មួយថ្ងៃ មានច្រើនណាស់ ដោយសារនៅប្រទេសនេះ មានតំបន់កោះច្រើន ហើយជើងយន្តហោះខ្លះត្រូវដេកចាំនៅព្រលានអស់មួយថ្ងៃពេញក៏មាន! និយាយរួម យើងអត់មានដានទេបងKen!

នាយKenក្តាប់មាត់ដោយស្មុគស្មាញ។ គេសួរបន្ត៖

-ចុះហេតុអីរាមនរិន្ទចាំដល់ថ្ងៃស្អែកបានចេញដំណើរ? មានតែវ៉ុលយន្តហោះនោះមានជើងហោះចេញពីហ្សាកាតាតែថ្ងៃស្អែក?

នាយឡុងតបវិញភ្លាម៖

-វ៉ុលចេញពីហ្សាកាតាមានរាប់ពាន់វ៉ុលក្នុងមួយថ្ងៃ ចំណែកវ៉ុលពិសេសដែលមានតែមួយ ឬពីរក្នុងមួយអាទិត្យ ហើយចេញចំថ្ងៃស្អែកមានជាង១០០ជើងឯណោះបង!

លំអងដកដង្ហើមធំ និយាយកាត់៖

-ឆែកFlight មិនមែនជាមធ្យោបាយទេ!

-ចុះធ្វើម៉េចវិញ? មិនដល់១២ម៉ោងទៀតទេ រាមនរិន្ទវានាំគ្នាចេញពីBaliហើយបើយើងរកមិនឃើញ យើងនឹងដាច់ដានត្រឹមហ្នឹងតែម្តង!

ឡុងឆ្លើយផ្ទួង៖

-យើងតាមដានពួកវានៅពេលចេញដំណើរតែម្តងទៅបងKen! ខ្ញុំទៅចាំនៅហ្សាកាតា ហើយឲ្យអាហ៊ូចាំមើលនៅព្រលានបាលី ហើយឲ្យដំណឹងខ្ញុំ!

នាយម្នាក់ទៀតដែលទើបមកដល់ជាមួយនាយឡុងនិយាយបន្តរឹង៖

-ខ្ញុំក៏គិតដូចអាឡុងដែរ! ហើយពេលដឹងព័ត៌មានភ្លាមយើងអាចជិះទៅជាមួយពួកវាតែម្តង ព្រោះពួកវាអត់ស្គាល់ពួកខ្ញុំទេ!

តែ Kenគ្រវីក្បាល គេនិយាយដោយទឹកមុខមិនសប្បាយចិត្ត៖

-ប្រើខួរក្បាលបន្តិចទៅពីរនាក់ឯងនេះ! ធ្វើការនៅព្រលានយន្តហោះមិនមែនងាយស្រួលទេ ពិសេសពេលគេ Check In រួច! នៅទីនេះ ប៉ូលិសInterpolនៅគ្រប់កន្លែងដោយសារវាជាទឹកដីដ៏ធំ

របស់មូស្លីម! យើងចង់ធ្វើអីក៏ពិបាកដែរ! ម្យ៉ាងទៀតបើឯងឆែកដឹងតើបានការអី ព្រោះបើជើងនោះកម្រចេញ មានន័យថាពេលចេញម្តងសំបុត្រលក់អស់ហើយ រឿងទិញសំបុត្រភ្លាមៗគឺគ្មានផ្លូវទេ!

លំអងនិយាយកាត់បុរសទាំងបី៖

-យើងមិនបាច់ចេញមុខទាំងអស់! ប្រើកេតឌីម៉ាទៀតទៅ!

-នេះក៏មិនមែនងាយដែរលំអង (Kenបដិសេធវិញ) រាមនរិន្ទ មិនមែនងាយស្រួលដល់ ថ្នាក់និយាយពីកន្លែងហ្នឹង ប្រាប់ស្រីល្ងង់របស់អូនឯងទេ! សូម្បីអាBirdនៅហ្នឹងយូរហើយ វានៅមិនដឹងអីបន្តិចផង!គេបិទជិតស្អាតណាស់រឿងហ្នឹង!

លំអងនិយាយតបដោយមិនរុញរា៖

-តែបើកេតឌីម៉ាត្រូវទៅទីនោះដែរ វាមុខតែដឹងថាវាត្រូវទៅកន្លែងណាមែនទេ?

Kenបើកភ្នែកមុតថ្លាសម្លឹងស្រីស្រស់ជាគូស្នេហ៍ គេពោលសួរវិញយ៉ាងរហ័ស៖

-ត្រូវ! តែធ្វើម៉េចឱ្យឌីម៉ាព្រមទៅតាមអាកូនតំណាងរាស្ត្រនោះ? ហើយបើទោះស្រីល្ងង់ហ្នឹងព្រម រាមនរិន្ទក៏មិនប្រាកដថាព្រមឲ្យវាទៅជាមួយដែរ!

លំអងសើចបង្ហាញថ្កាល់ខ្ទួច៖

-អញ្ចឹងហើយបានជាយើងត្រូវប្រើបញ្ញា!

លំអងដៀងភ្នែកសញ្ជឹងគិត ភាពភ្លឺចិញ្ចាចលេចឡើងតាមរយៈក្រសែភ្នែកនាងបង្ហាញឲ្យនាយKenដឹងថាស្រីៗប្រាកដជាមានមធ្យោបាយច្រើនជាងបុរសនៅការងារល្អិតល្អន់មួយចំនួន។

គេធ្វើដៃឲ្យសញ្ញានាយឡុង និងនាយហ៊ូចាកចេញទៅវិញ។លំអងដើរទៅកាន់បង្អួចហើយបើកវាំងននសម្លឹងទៅសួនច្បារខាងក្រោម។ នៅពេលដែលបន្ទប់សល់តែពីរនាក់តទល់ Kenដើរមកឱបចង្កេះស្រីស៊ីវិល័យរួចសម្លឹងទៅជាន់ខាងក្រោមដូចគ្នា។ នៅទីនោះ នារីសក់វែងម្នាក់កំពុងនាំកាយល្វតល្វន់ កំពុងរួសរាន់ដើរកាត់សួនច្បារចាកចេញទៅខាងក្រៅរបងសណ្ឋាគារ។ លំអងតាមសម្លឹងនាងមិនដាក់នៅពេលដែល Kenនិយាយតិចៗ៖

-កេតឌីម៉ាចេញទៅជួបរាមនរិន្ទហើយ!

លំអងសើចស្រស់តាមមើលដំណើរមិត្តស្រីរបស់ខ្លួនពីចម្ងាយ។ Kenនិយាយបន្ថែម៖

-ស្រីល្ងង់ហ្នឹងគិតថាអូនឯងកំពុងត្រូវគេចាប់ណ៎ា បានជាព្រមលុបចោលសំបុត្រយន្តហោះ នៅបាលីបន្ត! អូនឯងអត់មានចិត្តអាណិតវាអីបន្តិចទេលំអង?

លំអងក្ដាប់មាត់លើកដៃក្រសោបហត្ថាបុរសអភិជនដែលនៅលើចង្កេះខ្លួន។ នាងពោលតបភ្លាមៈ

-នរណាប្រើឲ្យខ្ញុំងប់ស្រលាញ់ចំតួចិត្តអាក្រក់ដូចបងKenធ្វើអី? ស្រីៗត្រូវធ្វើអ្វីគ្រប់យ៉ាងដើម្បីបុរសដែលនាងស្រលាញ់អញ្ចឹងហើយ! ណាមួយឲ្យកេតឌីម៉ាទៅនៅជាមួយរាមនរិទ្ធក៏មិនមែនមានន័យថាឲ្យស្រីល្ងង់ហ្នឹងទៅស្លាប់ឯណា? ឬមួយបងKenខ្លួនឯងទេដឹងដែលអាណិតស្រីស្អាតកេតឌីម៉ារបស់បងនោះ?

Kenសើចប្រកបដោយល្បិចកល។ មាត់នរៈអភិជននិយាយបន្តពីស្រីស្នេហ៍ៈ

-បងមិនមែនតួចិត្តអាក្រក់ទេលំអង! តែបងគឺជាតួឆ្លាតវ៉ៃ! ពិភពលោកនេះសម្រាប់តែមនុស្សឆ្លាតទេ ហើយក្នុងបេះដូងប្រុសឆ្លាតក៏មានតែស្រីឆ្លាតៗដូចលំអងដែរ!

គេឱនស្រង់ក្លិនពីផែនថ្ពាល់នារីស៊ីវិល័យបណ្ដាលឲ្យនាងរំភើបកាន់តែជឿទៅក្នុងពាក្យបញ្ជើច និងអារម្មណ៍ផ្អែមល្ហែម។ នាងប្រទ្បេះដៃគេចេញរួចបែរក្រោយមកប្រឈមមុខកៀកកិតក្បែរពាណិជ្ជករសង្ហា។ ស្ថិតនៅចំពោះមុខកែវភ្នែកស្រទន់របស់លំអង នាយKenសើចស្រទន់តបទៅរកនាង ហើយប្រើក្រសែភ្នែកទាញយកដួងព្រលឹងរបស់នាងតែម្ដង។

-ស្រីល្ងង់ហ្នឹង គ្មានកន្លែងណាប្រៀបជាមួយអូនបានទេលំអង!

នារីស៊ីវិល័យញញឹមស្រស់បង្ហាញស្នាមខួចថ្ពាល់ត្រដៃតបង្អួតភ្នែកអភិជនកំលោះពោរពេញដោយមហិច្ឆតា។ នាងជឿថាក្នុងបេះដូងKenមានតែខ្លួនមែនព្រោះគេមានចិត្តរឹងសូម្បីស្រីមានសម្រស់ ដូចកេតឌីម៉ាលង់ចិត្តយ៉ាងជ្រៅហើយក៏គេនៅតែមិនដែលប៉ះពាល់ដោយទុកផ្កា ស្រស់បំព្រងផ្ដាក់ទាក់បុរសមកពីគ្រួសារអ្នកនយោបាយវិញចំណែករាងកាយសែនសង្ហារបស់គេ គឺមកនែបនិត្យប្រលោមតែនាងម្នាក់រហូតដល់នារីលង់ក្នុងអន្ទាក់ស្នេហ៍ ហ៊ានក្បត់ទាំងមិត្តខ្លួនដែលស្លូតត្រង់នោះទៀត។

និយាយតិចៗតាមឥទ្ធិពលញាប់ញ័រនៃបេះដូងៈ

-ពេលបងKenបានឥន្ទប្បដិមាហើយ បងKenគិតធ្វើម៉េចទៀត?

អភិជនKenតបតដោយគ្មានទាក់ទើរៈ

-យើងនឹងស្វែងរកកន្លែងល្អបំផុតនៅលើលោកនេះសម្រាប់សោយសុខតែពីរនាក់! បងគឺជាស្តេច ហើយអូនគឺជាម្ចាស់ក្សត្រី! យើងទាំងពីរនឹងប្រើជីវិតលើគំនរសម្បត្តិមហាសាលលើសគេក្នុងលោកនេះ!

នារីញញឹមបិទភ្នែកក្នុងរង្វង់ដៃប្រុសស្នេហ៍ តែនាងនៅតែហើបមាត់សួរ៖

-វត្ថុបុរាណមួយហ្នឹងក្លាយជាសម្បត្តិមហាសាលដោយវិធីណាទៅ? យ៉ាងច្រើនណាស់វាអាចលក់បានប៉ុន្មានម៉ឺនដុល្លារប៉ុណ្ណឹងឯង!

នាយKenញញឹមមិនឆ្លើយតបនឹងសំនួរស្រីស្រស់ទេ ដោយសារគេគិតថាលើលោកនេះប្រហែលជាមានតែគេនឹងរាមនរិន្ទប៉ុណ្ណោះដែលដឹងពីអាថ៌កំបាំងរបស់ឥន្ទប្បដិមា នរាធិបតិន្ទ។ ដើម្បីបន្លប់សំនួររបស់លំអងគេធ្វើជាសួរវិញ៖

-បើសិនអូនអាចធ្វើឲ្យរាមនរិន្ទព្រមយកឪម៉ាទៅតាមក៏ដោយ ទម្រាំស្រីល្ងង់នោះឲ្យដំណឹងយើងពីទីកន្លែង យើងនៅតែមិនអាចចេញទៅតាមពួកវាទាន់ដែរ! បើរ៉ុលយន្តហោះនោះកម្រមានផង យើងអាចទៅដល់យឺតជាងពួកវាពីរបីថ្ងៃ ឬមួយអាទិត្យផងក៏មាន!

លំអងឆ្លើយមិនបង្អង់៖

អញ្ចឹងហើយបានជាអូនត្រូវទៅជាមួយពួកហ្នឹងដែរ!

Kenចងចិញ្ចើម។ គេយល់ថា មិនមែនងាយស្រួលទេក្នុងការឲ្យកេតឪម៉ាអាចតោងរាមនរិន្ទទៅកាន់តំបន់នោះបាន ចុះទម្រាំឲ្យលំអងអាចទៅជាមួយទៀត តើធ្វើយ៉ាងណាទៅបើនាងកំពុងស្ថិតក្នុងរូបភាពត្រូវចាប់ជំរិតនៅឡើយហ្នឹង?

ទោះយ៉ាងណាគេគិតថាបើលំអងហ៊ានអះអាង នាងប្រាកដជាមានវិធី។ ម្ល៉ោះហើយគេចាំបាច់ត្រូវពោលសរសើរនាង៖

-អូនឆ្លាតណាស់លំអង! តែកុំភ្លេចណ៎ា យើងសល់ពេលមិនច្រើនទេ! ហើយអូនកំពុងត្រូវគេចាប់ជំរិតនៅឡើយ!

ភាគទី១៦

ស្រមោលទិនករបាចសាចកាំរស្មីជាចុងក្រោយមុនពេលពេលចាកចោលសំណើចពិសពុលរបស់ប្រុសស្រីទាំងគូដែលកំពុងប្រើប្រាស់ចិត្តស្មោះភក្តីរបស់ស្ត្រីស្លូតត្រង់ម្នាក់មកធ្វើជាល្បែង និងលាភសក្ការៈ។

នៅពេលលំអង និងនាយKen កំពុងត្រេកត្រអាលនឹងល្បែងស្នេហ៍បន្ទាប់ពីសុខសាន្តចិត្តចំពោះផែនការថ្មីៗរបស់ខ្លួននោះ ស្រីស្រស់កេតឌីម៉ាក៏កំពុងប្រឈមមុខនឹងបរិយាកាសតឹងតែងសាជាថ្មី។

ក្នុងសម្លៀកបំពាក់សុភាពរាបសារ នារីប្រមុខកិន្នរីហ្វេស្សិនដែលត្រូវបានកូនចៅត្រឡប់ទៅចោលមុនអស់ បោះជំហានប្រញាប់ប្រញាល់កាត់តាមភោជនីយដ្ឋានចារ៉ាដ៏Romantic។

គោលដៅរបស់នាងគឺបុរសត្រកូលអ្នកនយោបាយដែលកំពុងឆ្លងកាត់អាហារពេលល្ងាចតែម្នាក់ឯងនៅតុកាច់ជ្រុងមួយឆ្ងាយពីអ្នកផង។ គ្រាន់តែក្រឡេកឃើញគេពីក្រោយ នាងចាប់ផ្តើមរវេសម្លាចបាត់ទៅហើយ ទម្រាំថាត្រូវទៅសុំជំនួយពីគេរឿងចាប់ជំរិតទៀត។ ប៉ុន្តែដើម្បីមិត្តភ័ក្តិដែលនាងគិតថាកំពុងស្ថិតនៅក្នុងចង្កូមមច្ចុរាជ ឌីម៉ាតាំងចិត្តបោះជំហានទៅមុខ។ នាងបានធ្វើឲ្យអភិជននានាក្នុងអាហារដ្ឋានពិសេសរបស់ជនជាតិចារ៉ាត្រូវក្រឡេកមកមើលគ្រប់គ្នាដោយសារពណ៌សម្បុរស្បែកពណ៌ទឹកឃ្មុំ និងរាងកាយទន់ល្វតដែលគេកម្ររកបាននៅទីនោះ។

រាមនរិន្ទអង្គុយប្រលែងលេងជាមួយកុំព្យូទ័រហើយព្រងើយកន្តើយជាមួយនិងចានម្ហូបម្ហានៅលើតុ ប៉ុន្តែគេមិនអាចធ្វើព្រងើយកន្តើយជាមួយក្លិនខ្លួនមនុស្សស្រីដែលគេនៅចំណាំបាននោះទេ។

អ្នកប្រុសត្រកូលខ្ពស់បែរក្រោយសម្លឹងម្ចាស់ក្លិនក្រអូបដែលមានវត្តមានក្រោយខ្នងពីពេលណាមកក៏មិនដឹង។ គេញញឹមមករកនាង តែចិញ្ចើមចងឡើងទៅលើតាមបែបងឿងឆ្ងល់៖

-កេតឌីម៉ា?

តរុណីដែលកំពុងកើតទុក្ខចង់ស្វាគមន៍ទៅរកនាយដោយស្នាមញញឹមគួរសមដែរតែទុក្ខព្រួយរបស់នាងមិនអាចឲ្យនាងធ្វើទៅរួចឡើយ។ ភាពរលើបរលោងដែលស្តែងចេញកាន់តែច្បាស់តាមរយៈពន្លឺភ្នែកមាណវីបង្ហាញម៉ូត បានធ្វើឲ្យចិត្តបុរសសង្ហាទៅជាក្តុកក្តួល។ គេជ្រួញចិញ្ចើមក្រោកឈរទាញកៅអីឲ្យស្រីស្អាតព្រមជាមួយសំនួរស្រាល៖

-មានរឿងអីកេតឌីម៉ា?

ដូចនាងគិតមែន គឺគេពិតជាធ្វើពើទោះបីនាយBirdបានដឹងរឿងលំអងត្រូវចាប់ជំរិតក៏ដោយ។ នេះបញ្ជាក់ថា សម្ដី Kenពិតជាត្រូវដែលថារាមនរិន្ទជាអ្នកនៅពីក្រោយអំពើចាប់ជំរិតនោះ ហើយហេតុផលរបស់គេគឺចង់ឲ្យនាងត្រឡប់មករកគេវិញដោយខ្លួនឯង។

នារីអង្គុយថ្នមៗមកទល់មុខបុរសមានអំណាច នាងឈ្ងោកមុខបណ្ដោយឲ្យទឹកភ្នែកស្រក់តក់ៗពីរតំណក់ដោយស្ងាត់ស្ងៀម។ នាងមិនមែនយំព្រោះពិបាកចិត្តរឿងមិត្តតែម្យ៉ាងទេ ប៉ុន្តែនាងខឹងចិត្តចំពោះកលល្បិចរបស់រាមនរិន្ទដែលចាប់បង្ខំមិត្តនាងហើយមកធ្វើពើមិនដឹងរឿង និងញញឹមធ្វើជាសុភាពបុរសជានិច្ច សំខាន់បំផុតដែលធ្វើឲ្យនាងត្រូវតែស្រក់ទឹកភ្នែកនោះ គឺកាលដែលដឹងការពិតហើយនាងនៅតែគ្មានលទ្ធភាពបកអាក្រាតនាយបានព្រោះមិត្តកំពុងស្ថិតក្នុងដៃគេ។

តែនាងមិនដឹងទេថា ទឹកភ្នែកពីរដំណក់របស់នាងបានធ្វើឲ្យអភិជនរូបល្អទៅជាច្របូកច្របល់។ គេរុញកុំព្យូទ័រទៅម្ខាង ហើយស្រវារកក្រដាសឲ្យនាងផ្ចិតទឹកភ្នែក។

នារីបង្ហាញម៉ូដខំទប់ភាពទោមនស្សកុំឲ្យគេមើលមកថាខ្លួនទន់ជ្រាយពេក តែដំណក់ទឹកភ្នែកដែលហូរមកស្ងៀមស្ងាត់គ្មានសំណោកសោយសោកវាកាន់តែបញ្ជាក់ពីសេចក្ដីឈឺចាប់ហួសពណ៌នាដែលចាំបាច់ឲ្យរាមនរិន្ទត្រូវតែលូកដៃស្ដាំមកត្រកងនាងឱបជាប់លង្វែកទ្រូង។ ពេលនោះហើយដែលគេអាចស្ដាប់ឮសព្ទខ្សឹកខ្សួលរបូតចេញពីមាត់នាងបាន ដោយសារនាងលែងអាចទប់ជាប់។

បុរសមានអំណាចឈ្ងោកមកក្បែរថ្ពាល់នារីសរូបស្អាតដែលមិនហ៊ានរើបម្រះពីរង្វង់ដៃនាយដោយនិយាយតិចៗក្បែរត្រចៀកនាង៖

-គ្មានអ្វីដែលដោះស្រាយមិនចេញទេកេតឌីម៉ា! និយាយមក! មានរឿងអី? ក្រែងថាត្រូវឡើងយន្តហោះយប់នេះអ្ហស់?

នារីរងគ្រោះដោយល្បិចបញ្ឆោតចាក់ស្រេះ បែរជាយល់ថារាមនរិន្ទព្យាយាមធ្វើពើ ដូច្នេះនាងមានតែមធ្យោបាយមួយគត់ គឺចាក់បណ្ដោយតាមគេ។

-លោកប្រុសរាម! គេចាប់លំអង! គេចាប់លំអងល្ងាចមិញបាត់ហើយ! លោកប្រុសរាមជួយផង!

រាមនរិន្ទបើកភ្នែកមូលក្លំពិចារណាលើព័ត៌មានដែលរបូតចេញពីមាត់ស្រីស្អាត។ ទន្ទឹមនឹងនោះនាងបានហុចSMSជំរិតទារប្រាក់មកឲ្យអ្នកមើលបន្ថែមដែរកុំឲ្យពេលវេលាអូសបន្លាយយូរ។ បុរសមានអំណាចហាក់មិនសម្ដែងការភ្ញាក់ផ្អើលខ្លាំងលើហេតុការណ៍អកុសលនេះទេ ដោយសារគេមាន

ទម្លាប់ជាមនុស្សស្ងប់ស្ងៀមប៉ុន្តែប្រការនេះបែរជាធ្វើឲ្យកេតឌីម៉ាកាន់តែយល់ខុសថារាមនរិន្ទមិនភ្ញាក់ផ្អើលព្រោះគេជាអ្នកនៅពីក្រោយរឿងនេះ។

ស្រីស្រស់ចិត្តត្រង់ងើបមុខចេញពីទ្រូងបុរសអភិជន រួចសម្លឹងមុខគេហាក់ចង់មើលឲ្យធ្លុះដល់បេះដូងបុរសអ្នកមានប្រាក់ដែលនាងយល់ថាពោរពេញទៅដោយល្បិចកល។ នាងនិយាយថ្នមៗ៖

-លោកប្រុសរាម! មេត្តាជួយផងទៅ! ខ្ញុំសូមអង្វរ!

រាមនរិន្ទញញឹម បក់ដៃហៅអ្នកផ្ទាល់សេវាកម្មឲ្យយកចានកែវមកថែមនៅចំពោះក្រសែភ្នែកមូលហ្មងរបស់ស្រីស្រស់។

-ញ៉ាំបាយទៅ! ខ្ញុំរកគេដោះស្រាយរឿងលំអងឲ្យ!

កេតឌីម៉ាដកដង្ហើមយូរធូរទ្រូងទោះបីនាងគិតថារាមនរិន្ទមានល្បិចច្រើនក៏ដោយតែបើគេសន្យាថាគេនឹងជួយហើយ គេប្រាកដជាដោះលែងលំអងមកវិញដើម្បីបង្ហាញពីប្រសិទ្ធភាពនៃការងាររបស់គេ។

នាងលូកដៃចាប់សមនិងស្លាបព្រាបន្ទាប់ពីកំលោះសង្ហាបានដាក់ម្ហូបចាវ៉ាំពណ៌ក្រហមក្រមៅទៅលើចានរបស់នាង។

បាយលាយទឹកភ្នែកប្រាកដជាមិនឆ្ងាញ់ទេ តែបើនាងមានៈមិនព្រមធ្វើឲ្យគេសប្បាយចិត្ត នាងនឹងមិនអាចជួបលំអងជារៀងរហូតម្ល៉េះហើយនាងត្រូវតែបង្ខំចិត្ត។

-អរគុណលោកប្រុសរាម!

នរៈញញឹមគេតបវិញមុនពេលក្រោកចេញទៅទូរស័ព្ទ៖

-កុំព្រួយអី អត់មានថ្នាំងងុយដេកទេ! យប់នេះឌីម៉ាអាចអង្គុយចាំដំណឹងពីលំអងបានមួយសេរី!

គេបែរខ្នងដើរចេញទៅនិយាយទូរស័ព្ទទុកអោយតរុណីយើងនៅស្រឡាំងកាំងម្នាក់ឯង។

"គេដឹងថាយើងដាក់ថ្នាំក្នុងទឹកគេកាលពីម្សិលមិញទៀត? នេះឬវិធីដែលលោកសងសឹកខ្ញុំរាមនរិន្ទ?"

ធីតាឱនសម្លឹងចានម្ហូបទាំងខ្វល់ខ្វាយ។ នាងមិនដឹងថារាមនរិន្ទនឹងធ្វើយ៉ាងណាចំពោះខ្លួនទេពិសេសពេលនេះនាងគ្មាន អ្វីជាជំនួយទាំងអស់ព្រោះសូម្បីតែថ្នាំងងុយក៏គេដឹងដែរនោះ។

កេតឌីម៉ាងើបមុខសម្លឹងបុរសដែលនាងយល់ថាគួរឲ្យខ្លាចជាងជនពាលក្នុងភាពយន្ត។ គេកំពុងនិយាយទូរសព្ទចាត់ចែងដោះស្រាយរឿងបាត់ខ្លួនរបស់លំអងតែនាងយល់ថាគេកំពុងលេងល្បែងឆ្កិនភ្នែក។

នាងឈ្ងោកមុខចុះវិញភ្លាមនៅ ពេលឃើញគេឈប់ទូរសព្ទហើយដើរត្រឡប់មកវិញ។

-គេកំពុងធ្វើការហើយ! យប់នេះចាំស្តាប់ដំណឹងជាមួយគ្នានៅទីនេះចុះឌីម៉ា!

"បងKenបងនិយាយត្រូវណាស់! តាមពិតគ្រប់បែបយ៉ាងជាមធ្យោបាយរបស់រាមនរិន្ទក្នុងការបង្ខំខ្ញុំឲ្យនៅជាមួយគេ។ តើយប់នេះខ្ញុំត្រូវឆ្លងកាត់ដោយរបៀបណាទៅ? "នាងគិតម្នាក់ឯងដូចកូនសត្វដែលកំពុងជាប់ក្នុងទ្រុងហើយទាល់ច្រក។

ទោះបីមិនអាចប្រៀបជាមួយAmandariប៉ុន្តែនៅបន្ទប់ស្នាក់នៅរាត្រីនេះក៏ស្ថិតក្នុងលំដាប់ស្ងួតសម្រាប់អ្នកក្រៅសង្វៀនអភិជនដែរ។ កេតឌីម៉ាដើរមកតាមរាមនរិន្ទទាំងដឹងហើយថានាងកំពុងដើរចូលមាត់ក្រពើ។ ចប់តាមផ្លូវនាងគិតថា នាយKenបារម្ភពីនាង មិនឲ្យនាងមកផ្សងគ្រោះថ្នាក់ទៀតទេតែនាងត្រូវតែដោះស្រាយចំណងនេះដើម្បីលំអងដែលគ្មានកំហុស។ កាន់តែគិត រូបភាពរាមនរិន្ទកាន់តែអាក្រក់ឡើងៗក្នុងបេះដូងបរិសុទ្ធរបស់នារីស្មោះត្រង់។

ចូលមកដល់បន្ទប់សណ្ឋាគាររបស់បុរសនេះកាលណា នាងមានអារម្មណ៍ដូចត្រូវធ្លាក់ក្នុងភាពងងឹតងងល់សាជាថ្មី។

"កេតឌីម៉ា តើឯងមានកម្មអីជាមួយបុរសចិត្តកំណាចនេះ? "នាងសួរខ្លួនឯងទាំងអស់សង្ឃឹម។ សូរទូរសព្ទលាន់មករន្ថើននៅខណៈនារីទើបតែឈានយឺតៗចូលមកក្នុងបន្ទប់គេងរបស់រាមនរិន្ទ។ បុរសអភិជនដើរហួសទៅកាន់តុធ្វើការរបស់គេជាមួយកុំព្យូទ័រក្នុងដៃទុកឲ្យស្រស់ស្រីនៅលើកទូរសព្ទមកទទួលដោយទឹកមុខស្រងូត។ នាងសម្លឹងទៅអេក្រង់រួចប្រែជាបើកភ្នែកធំៗព្រោះភ្ញាក់ផ្អើល។កេតឌីម៉ាភ្លាត់មាត់៖

-លំអង?

សំឡេងនាងមិនខ្លាំងពេកតែក៏មិនខ្សោយដែរ។ លាយឡំនឹងសំឡេងបែបរន្ធត់ផងធ្វើឲ្យរាមនរិន្ទដែលនៅឆ្ងាយប្រមាណជាង១០ម៉ែត្រ នៅតែអាចស្តាប់ឮហើយងាកមកសម្លឹងនាងភ្លាម។

នរៈអភិជនតាមមើលសកម្មភាពនារីបង្ហាញម៉ូតដែលកំពុងប្រើដៃទាំងពីរផ្ទឹបទូរសព្ទទៅនឹងត្រចៀកហាក់ខ្លាចរបូតបាត់។ គេកាត់យល់បានថានាងកំពុងតែនិយាយជាមួយអ្នកណាម្នាក់ដែលសំខាន់

ណាស់ពិសេសនាងស្រែកឈ្មោះលំអងអម្បាញ់មិញផង ធ្វើអោយអ្នកប្រុសសង្ស័យថា អ្នកនៅឯចុងម្ខាងទៀតជាមនុស្សស្រីដែលមុននេះកេតឌីម៉ាអះអាងថា ត្រូវបានគេចាប់ជំរិតនោះ។

គេដាក់កុំព្យូទ័រទៅលើតុធ្វើការ ហើយបោះជំហានធ្ងន់ៗមករកស្រស់ស្រី។

-ហើយឥឡូវនេះ.....ឯង.......ឯងនៅឯណា?

នាងនិយាយទូរសព្ទបណ្ដើរងើបមុខសម្លឹងមករាមនរិន្ទដោយខ្សែភ្នែកតក់ស្លុតបណ្ដើរ។ មិនដឹងដែលទូរសព្ទមកនិយាយថាម៉េចទៀតនោះទេ រាមនរិន្ទឃើញនារីបង្ហាញមុំតនិយាយដាច់ៗតបវិញ៖

-អូខេ! ប៉ុណ្ណឹងចុះលំអង!

នាងដាក់ទូរសព្ទចុះសន្សឹមៗនៅពេលដែលរាមនរិន្ទដើរទៅដល់ល្មម។ អ្នកប្រុសសង្កាសម្លឹងទៅពន្លឺភ្នែកដ៏រំជើបរំជួលរបស់នាង។ ទោះនាងមិនប្រាប់ ក៏អ្នកអាចដឹងថាអ្នកដែលទូរសព្ទមកនោះជាលំអងដែរ។ គេពោលសួរតិចៗ៖

-ក្រែងត្រូវគេចាប់អ្វី?

កេតឌីម៉ា ដកដង្ហើមយូរឲ្យធូរចិត្តមុននឹងឆ្លើយតបសំនួរម្ចាស់បន្ទប់៖

-គឺ....គឺ....នាងអស់អីហើយ!

រាមនរិន្ទចងចិញ្ចើមតិចៗរបៀបឆ្ងល់។ គេលូកដៃកៀកចង្កេះស្រី ស្អាតបណ្ដើរនាងទៅ រកកន្លែងអង្គុយ។ ឌីម៉ានិយាយរៀបរាប់ប្រាប់ បុរសត្រកូល អ្នកនយោបាយតាមអ្វីដែលលំអងបានប្រាប់អម្បាញ់មិញនេះថា នាងត្រូវបុរសបីនាក់ចាំដាក់រថយន្តមួយហើយបោះពួយចេញទៅក្រៅក្រុង។ លុះដល់ល្ងាចមិញនេះនាងស្រាប់តែដឹងខ្លួនឡើងវិញដោយឃើញខ្លួនឯងត្រូវគេទម្លាក់ផ្ដុងចោលនៅតំបន់ឆ្នេរស្ងាត់ជ្រងំមួយចំណែកទ្រព្យសម្បត្តិផ្ទាល់ខ្លួនក្នុងកាបូបស្ពាយត្រូវបាត់អស់រលីងហើយ។

កេតឌីម៉ាមិនបានដឹងទេថា នេះជាកលល្បិចជំហានថ្មីរបស់លំអង និងKen។ ផ្ទុយទៅវិញនាងបែរជាយល់ថា គឺនាងមករករាមនរិន្ទទើបគេព្រមលែងលំអងមកវិញ។ ដល់មកឮគេសួរធ្វើពើទៀត នាងធ្វើជាឆ្លើយតបតាមដំណើរ ប៉ុន្តែក្នុងចិត្តកំពុងខឹងក្នាញ់រកទីបំផុតគ្មាន។

នាងយល់ថារាមនរិន្ទពិតជាមានចេតនាធ្វើបាបអោយនាងត្រឡប់មករកគេដូចដែលបងKenរបស់នាងគិតមែន។ គេចាប់លំអងទៅ បន្ទាប់មកធ្វើជាជំរិតទារប្រាក់ហើយពេលនាងមកសុំជំនួយគេក៏ធ្វើជាលែងមិត្តនាងបំបាត់ដាន។

ដោយឡែករាមនរិន្ទដែលមិនបានដឹងរឿងរ៉ាវជ្រៅជ្រះបែរជាសួរនាងវិញ៖

-អញ្ចឹងពួកហ្នឹងផ្ញើ SMSមកទារប្រាក់ធ្វើអី?

តរុណីនៅទីទើរ។ នាងពិតជាមិនដឹងត្រូវឆ្លើយតបថាយ៉ាងណាមែន ព្រោះសូម្បីតែនាងខ្លួនឯងក៏មិនយល់។ ប៉ុន្តែដោយឃើញនាងមានអារម្មណ៍មិនល្អពេក រាម នរិន្ទក៏ទុកចម្ងល់នោះមួយអន្លើសិន ដោយស្ម័គ្រចិត្តជូននារីរូបល្អទៅកមិត្តភក្តិនាងទាំងយប់។ នាយBirdបើកឡានជូនស្រីស្រស់ប្រុសសង្ហាទៅដល់ហាងភេសជ្ជៈតូចមួយក្បែរផ្លូវលំក្នុងសម្លៀកបំពាក់ប្រឡាក់ស្រម៉ក និងទឹកមុខស្លេកស្លាំងស្មុះមករកនារីជាមិត្តដោយអំណរ។ ដោយឃើញវត្តមាននាងមានអមមកនូវបុរសអភិជនផងលំអងកាន់តែបានចិត្តសម្តែងល្ហៃនយំគគ្រូក។

កេតឌីម៉ាឱបមិត្តលួងលោម។ នាងក៏ស្រក់ទឹកភ្នែកតក់ៗអាណិតមិត្តគិតថាលំអងរងគ្រោះ ព្រោះតែបញ្ហារវាងនាង និងរាមនរិន្ទតែប៉ុណ្ណោះ។

ឌីម៉ានិយាយដោយអណ្តឺតអណ្តក៖

-លំអង! គេមានធ្វើបាបឯងទេ?

លំអងគ្រវីក្បាលដោយទឹកភ្នែក៖

-អត់ទេឌីម៉ា! គ្នាអរណាស់ដែលឯងមក! គ្នាភ័យណាស់ ខ្លាចពួកវាត្រឡប់មកវិញ!

រាមនរិន្ទសួរភ្លាម៖

-ចំណាំមុខពួកហ្នឹងបានខ្លះទេលំអង?

លំអងងើបមុខមករកបុរសអភិជនទាំងទឹកភ្នែកសស្រាក់។ នាងឆ្លើយតប៖

-អត់ទេ! ពេលនោះច្របូកច្របល់! ពួកវាចាប់ខ្ញុំទៅក្នុងឡានហើយខ្ទប់មាត់ច្រមុះខ្ញុំ ខ្ញុំក៏លែងដឹងខ្លួន! ទើបតែដឹងខ្លួនមុននេះហើយរត់មកផ្លូវធំទាក់ទងឌីម៉ាភ្លាម!

រាមនរិន្ទសួរបន្ថែមដោយងឿងឆ្ងល់៖

-កាលពីព្រឹកមានគេSMSមកទារលុយឌីម៉ា! ចុះបើគេចង់បានលុយម៉េចសុខៗគេលែងលំអងមកវិញ?

លំអងធ្វើមុខងឺងើតាមបែបមិនដឹងរឿងដូចគ្នា ផ្ទុយទៅវិញកេតឌីម៉ាខំប្រឹងសម្លឹងរាមនរិន្ទយ៉ាងមុត ដើម្បីឲ្យដឹងថា គេកំពុងលេងស្នៀតអីទៀត។ នាងនៅតែគិតរាមនរិន្ទនៅពីក្រោយការចាប់នេះ ហើយធ្វើសារបង្ខំឲ្យនាងទ័លច្រក បន្ទាប់មកពេលនាងទៅរកគេឲ្យជួយ គេក៏ឲ្យបក្សពួកផ្លុងលំអង ចោលវិញ។ ពេលនេះគេបែរជាមកបង្កើតសំនួរធ្វើបែបមិនដឹងរឿង ធ្វើឲ្យនាងកាន់តែយល់ថាបុរស នេះមានល្បិចច្រើនណាស់។

ខណៈដែលនាងនៅស្ងៀម នាងបែរជាឮលំអងនិយាយបន្ថែម៖

-ប្រហែលជាពួកហ្នឹងគិតថាខ្ញុំស្លាប់ ឬមួយខ្លាចប៉ូលិសទេដឹងបានជាប្រញាប់បញ្ចប់រឿង?

រាមនរិន្ទងក់ក្បាល៖

-ល្អណាស់ដែលអត់អី! ប៉ុន្តែយើងគួរតែរាយការណ៍ឲ្យប៉ូលិសទៅ!

លំអងប្រញាប់ពោលឃាត់ភ្លាម៖

-អត់ទេលោកប្រុសរាម! កុំឲ្យវែងឆ្ងាយ! ខ្ញុំខ្លាចណាស់! ខ្ញុំមិនចង់ទេ!

នារីជើងល្អធ្វើជាស្ទុះឱបឌីម៉ារួចយំសស្រាក់យ៉ាងស្ទាត់ជំនាញ។ ឃើញមិត្តភ័ក្តិភ័យដល់ថ្នាក់ញ័រដៃ ជើង ឌីម៉ាកាន់តែអាណិតខ្លោចចិត្ត។ នាងឱបមិត្តពេញរង្វង់ដៃដោយទឹកភ្នែករលីងរលោង។ រាម នរិន្ទលែងបញ្ចេញយោបល់។ គេនាំនារីទាំងពីរត្រឡប់ទៅកាន់កន្លែងស្នាក់នៅរបស់នាងវិញ។

មកដល់សណ្ឋាគារដែលខ្លួនស្នាក់នៅ នាងក្រមុំដឹងថាអាចផុតពីកណ្តាប់ដៃរាមនរិន្ទបានហើយទើប នាងប្រញាប់ប្រញាល់ផ្តុំដៃជម្រាបលាគេតាំងពី នៅជាន់ខាងក្រោមព្រមទាំងពោលពាក្យអរគុណ យ៉ាងទន់ភ្លន់ផងដោយសង្ឃឹមថា គេនឹងព្រមត្រឡប់ទៅវិញដឹងអីរាមនរិន្ទនៅតែមានៈជូននារីទាំង ពីររហូតដល់បន្ទប់។

អ្វីដែលឌីម៉ាខ្លាចបំផុតគឺខ្លាចលំអង និងរាមនរិន្ទបានជួបនាយKenសំណព្វចិត្តខ្លួន។ ទោះបីថានាង និងពាណិជ្ជករដេកថៃបនោះមិនដែលបានឆ្លងរំលងប្រពៃណី ប៉ុន្តែបុរសនោះដែលបង្ហាញខ្លួនដូច អំពិលអំពែកនៅបាលីតែងតែមានវិធីចូលមកចាំជួបនាងពិភាក្សាគ្នាពីផែនការផ្សេងៗក្នុងបន្ទប់នាង សម្រាកតែម្តងដើម្បីគេចពីភ្នែកកូនចៅរាមនរិន្ទ។

ដោយមិនដឹងសោះថាលំអង និងKenមានទំនាក់ទំនងស៊ីជម្រៅនឹងគ្នានោះ ឌីម៉ាបែរជាយល់ថានៅទីនេះមានតែនាងម្នាក់គត់ដែលបានជួបKenហើយនាងក៏មិនចង់ឲ្យរឿងនេះដឹងឮដល់អ្នកទី៣ដែរ ទោះជាមិត្តខ្លួន ឬរាមនរិន្ទក្តី។

ភាគទី១៧

មកដល់មាត់ទ្វារបន្ទប់នាងហើយ រាមនរិន្ទនៅតែមិនព្រមបកក្រោយសោះ តាមពិតគឺគេបារម្ភពីសុវត្ថិភាពពួកនាងជាស្រីបន្ទាប់ពីក្រុមការងារបានវិលត្រឡប់ទៅកម្ពុជាវិញចោលអស់ទៅហើយ ហើយមានរឿងចម្លែកៗកើតឡើងផង។

គេនៅឈររេរារង់ចាំពួកនាងចូលផុតក្នុងបន្ទប់ទើបដាច់ចិត្តចាកចេញទៅវិញប៉ុន្តែឌីម៉ានៅទីទើរមិនព្រមបើកសោសោះព្រោះនាងខ្លាចបុរសនេះចូលទៅក្នុងនោះដែរ។

-ឆាប់បើកទ្វារទៅកេតឌីម៉ា?(រាមនរិន្ទនិយាយ)

ស្រីស្រស់ទីទើរ។ នាងសួរខ្លួនឯងតិចៗ៖

"បងKenអើយបងKenនៅក្នុងហ្នឹងដែរអត់? បើគេឃើញបង គេដឹងពីផែនការយើងអស់ហើយ!"។

លំអងឃើញមិត្តនារីទីទើរហើយប៉ុន្តែដោយសារនាងមានផែនការផ្សេងនាងក៏រួមដៃជាមួយរាមនរិន្ទក្នុងការតឿនកេតឌីម៉ា៖

-បើកសោទៅឌីម៉ា!

ឌីម៉ាគ្មានជម្រើសបដិសេធទេ។ នាងមួលសោរួចរុញទ្វារចូលសន្សឹមៗ។ រាមនរិន្ទដើរកាត់ពីមុខលំអងឆ្ពោះទៅក្នុងបន្ទប់មុនតាមពិតគេចង់ពិនិត្យមើលក្រែងមានអ្វីមិនប្រក្រតី ឬមាននរណាបន្លំខ្លួននៅក្នុងនោះរង់ចាំធ្វើបាបនារីទាំងពីរប៉ុណ្ណោះតែកេតឌីម៉ាបែរជាភ័យ និងធុញទ្រាន់យ៉ាងខ្លាំងព្រោះនាងមិនដែលចង់ឲ្យបុរសនេះឈានជើងចូលក្នុងទីឯកជនរបស់នាងឡើយ។

នាងតាមសម្លឹងសកម្មភាពរាមនរិន្ទដែលឈានចូលទៅក្នុងបន្ទប់នាង ដោយឃើញទឹកមុខគេប្រែទៅជាថ្លោះនាងចាប់ភ័យក្តុកក្នុងចិត្ត។

"គេឃើញបងKenហើយ"

រាមនរិន្ទឈានតិចៗចូលទៅទៀតដោយទឹកមុខចម្លែក មិនភ័យតែក៏មិនធម្មតា។ កេតឌីម៉ាភ័យណាស់ តែនាងមិនអាចគេចបានទេ នាងត្រូវតែដើរចូលយឺតៗទៅតាមពីក្រោយគេ។

......ស្រីស្រស់បង្ហាញមុំតភ្ញាក់ក្រញាងនៅពេលដែលផ្ទៃបន្ទប់ទាំងមូលរបស់នាងប្រែទៅជាខ្ទាត់ខ្ទាយសម្ភារៈខ្ទេចខ្ទីប្រៀបបីដូចជាទើបតែត្រូវបានបំផ្លាញដោយដៃអ្នកណាគេម្នាក់។

សូម្បីតែកម្រាលភួយ និងកម្រាលពូកលើគ្រែដែលនាងធ្លាប់គេងក៏ត្រូវវះជាឆ្នូតវែងៗដោយមុខកាំបិតដែរ។ ស្រស់ស្រីលើកដៃខ្ទប់មាត់ដោយរន្ធត់។

រាមនរិទ្ធលើកដៃចុចទូរសព្ទរួចនិយាយៈ

-Bird នាំសន្តិសុខ និងអ្នកគ្រប់គ្រងសណ្ឋាគារឡើងមកបន្ទប់កេតឌីម៉ាភ្លាម!

នារីរូបស្រស់ និងកម្លោះចិត្តបុណ្យមិនបានដឹងទេថា នេះគឺជាជំហានបន្ថែមរបស់លំអង និងKen ដែលបង្ខំរាមនរិទ្ធត្រូវតែទទួលកេតឌីម៉ាទៅនៅក្បែរខ្លួន។ ឆ្លៀតពេលដែលនាងមិននៅគេបាននាំគ្នាឡើងមកចិញ្ច្រាំបំផ្លាញបន្ទប់នេះ ហើយឲ្យលំអងទាក់ទាញបានរាមនរិទ្ធមកដល់ឃើញដើម្បីឲ្យគេកាន់តែជឿថាសុវត្ថិភាពនារីទាំងទ្វេកំពុងរងការគំរាមប្រាកដណាស់ ដូច្នេះចុងបញ្ចប់នារីទាំងពីរត្រូវបានទទួលឲ្យទៅនៅកៀកនឹងរាមនរិទ្ធតែម្តង។

ទុកឲ្យប៉ូលិស និងខាងសណ្ឋាគារជាអ្នកធ្វើការទាក់ទងនឹងរឿងកាប់ចិញ្ច្រាំបន្ទប់ដេកនោះ ចំណែករាមនរិទ្ធបាននាំនារីទាំងពីរមកនៅសណ្ឋាគារជាមួយដែលមានបន្ទប់នៅក្បែរគ្នាតែម្តង។

## វគ្គទី៩

## រាត្រីចុងក្រោយនៅបាលី

សត្វរាត្រីចរក៏ស្ងាត់បាត់សំឡេងដែរកុំថាឡើយមនុស្សម្នាដែលត្រូវតែចូលនិទ្រានាពេលរាត្រីរំលងអាធ្រាត្រនោះ។ ប៉ុន្តែនៅក្រោមបរិយាកាសស្ងាត់សូន្យសុងបានលួចបង្កប់នូវគូសន្ទនាពីររូបដែលពោរពេញដោយទុក្ខកង្វល់ស្រាយមិនចេញ។

-ថាម៉េចលំអង? ថ្មើរណេះហើយឯងគិតចង់ឲ្យគ្នាចូលទៅរកគេទៀត? ឯងភ័យដល់ថ្នាក់ឡប់ សតិហើយអ្វី?

ឌីម៉ានិយាយដោយលើកភួយទទូរគ្របមុខព្រោះគ្រាន់តែឮសូររឿងបន្ទប់រាមនរិទ្ធនាងចាប់ផ្តើមមានអារម្មណ៍អាក្រក់បាត់ទៅហើយ។ ប៉ុន្តែនារីជាមិត្តដែលបានសម្រេចផែនការក្នុងការនាំឌីម៉ាមកស្នាក់នៅបន្ទប់ជាប់ជញ្ជាំងជាមួយរាមនរិទ្ធ ហើយក្តីនៅតែមិនបោះបង់ចោលការព្យាយាមក្នុងការបញ្ចុះបញ្ចូល ឌីម៉ាឲ្យលុះក្រោមផែនការបន្ទាប់របស់ខ្លួនឡើយ។

លំអងលូកដៃទាញភួយចេញពីមុខមិត្តរួចនិយាយបន្តៈ

-នែ៎ឪម៉ាឯងកុំគិតថាយើងបានរួចខ្លួនណ៎ា! ឥឡូវនៅបាលីសល់តែពីរនាក់យើងទេ! គ្នា...គ្នាភ័យណាស់...សូម្បីបន្ទប់ឯងដេកក៏វាចូលទៅរើកកាយខ្ទេចខ្ទីដែរ..មិនដឹងថាវាជាអ្នកណាផង...យើងនៅកន្លែងភ្លឺវានៅកន្លែងងងឹត! ឯងមានតែផ្លូវមួយទេ គឺរកលោកប្រុសរាមឲ្យការពារពួកយើង!

ឪម៉ាងាកមុខចេញធ្វើជាបិទភ្នែកៈ

-ចុះឥឡូវ ក្រែងគេនោះការពារយើងហើយតើអ្វី? ដេកទៅ! យប់ហើយ!

-តែដល់ពេលបានរួចខ្លួនឯងមកដេកធ្វើព្រងើយមិនរវល់នឹងគេអញ្ចឹងអ្វីឪម៉ានាងឆ្កួត? (លំអងខ្សឹបបន្ទោស)

ឪម៉ាហួសចិត្តនាងងាកមកពោលសួរវិញដោយទឹកមុខងឿងឆ្ងល់ៈ

-ហើយចុះឯងគិតចង់ឲ្យគ្នាទៅធ្វើម៉េចទៀត? ពាក្យអរគុណនិយាយរួចហើយទេតើ? នេះកណ្ដាលអាធ្រាត្រហើយណ៎ាលំអង! ឯងយល់សប្តិមិនមែន?

លំអងចចេសទាញឪម៉ាអោយក្រោកទោះជាមិត្តកំពុងបង្ហាញភាពងោគងុយក៏ដោយៈ

-នែ៎ឪម៉ា! គេជួយឯងចោលបាយចោលទឹក! ថ្មើរណោះមិនទាន់ដឹងបានអីទ្រាប់ក្រពះបន្ថែម ឬមួយគេងទាំងអត់បាយផងមិនដឹង! ដល់បានសុខសាន្តឯងគិតធ្វើមិនដឹងមកដេកវាហ៊ីអញ្ចឹង? កុំភ្លេចណ៎ាគ្រោះថ្នាក់នៅជិតៗបង្កើយទេ ប្រយ័ត្នលើកក្រោយរត់ទៅរកគេទៀតគេលែងជួយ! ពិសេសគេខំជួយឯងមកដេកធ្វើហ៊ីចោលគេអញ្ចឹង ពេលជួបគេលើកក្រោយ ឯងមានមុខមើលគេដែរ?

ឪម៉ាស្ងាបហាមៗនាងពោលតបៈ

-លំអងអើយលំអង! គេថាឆ្មាធ្លាប់ត្រូវទឹកក្ដៅ ដល់តែមកត្រូវទឹកត្រជាក់ក៏វាខ្លាច! ឯងគឺដូចពាក្យគេនិយាយនោះបេះបិទ! ឯងភ័យដល់ណាក៏មិនគួរអត់ប្រើបញ្ញាដែរពួកម៉ាក! ស្អែកនេះគេចេញពីបាលីហើយ! ឮអត់? យើងក៏មិនបាច់ជួបមុខគេនាំទើសទាល់ទៀតដែរ! តោះដេក!

នាងប្រុងប្រាសទៅវិញតែលំអងទាញជាប់ៈ

-គេចេញទៅណា?....គេចេញពីបាលីនេះអ្វី? ទោះយ៉ាងណាឯងត្រូវតែទៅសុំគេឲ្យយកយើងទៅជាមួយណ៎ាឪម៉ា!

ក្រមុំប្រមុខកន្ទររីហ្វស៊ិនបើកភ្នែកធំនៅពេលឮសម្ដីចុងក្រោយរបស់មិត្ត។ នាងលូកដៃស្ទាបក្បាលលំអងរួចនិយាយលាយសើចខឹះដោយហួសចិត្តៈ

-ឯង..ឯងក្ដៅខ្លួនដល់វង្វេងហើយអ្វី? ហេតុអីឯងចង់ទៅតាមពួកគេអ៊្ហាលំអង?

លំអងធ្វើល្ងើនឆ្កិនភ្នែកតាមរយៈទឹកមុខស្លន់ស្លោ ព្រួយបារម្ភៈ

-ព្រោះបើគេទៅបាត់បានអ្នកណាការពារពួកយើង!

កេតឌីម៉ាបន្លឺតបវិញយ៉ាងរហ័សៈ

-យើងអត់ត្រូវការទេ! យើងឆាប់ទិញសំបុត្រថ្មីហើយចេញទៅកម្ពុជាវិញព្រឹកស្អែកនេះទៅ! អូខេ! បើថាឯងអន្ទះសាណាស់ ភ័យណាស់ ខ្ញុំខលទៅខាងក្រោមឲ្យបុគ្គលិកសណ្ឋាគារចាត់ការរឿងសំបុត្រឲ្យយើងឲ្យហើយ! ខ្ញុំប្រាប់ឯងណាលំអង! ខ្ញុំក៏ធុញដែរនៅទីនេះ! ព្រឹកមិញខ្ញុំចោល ជើងយន្តហោះដោយសារខ្វល់រឿងឯងហ្នឹងហើយ! ឥឡូវពួកគេនោះគេបន្តទៅកន្លែងផ្សេងទៀត យើងមានរឿងអីត្រូវទៅតាមគេអ្ហះ? ខ្ញុំត្រូវការត្រឡប់ទៅផ្ទះវិញ! គឺទៅភ្នំពេញ! តែ១ថ្ងៃទៀតក៏គ្នាមិននៅដែរ!

លំអងស្រែកយំដ៉ោងលែងនិយាយស្ដី។ ឌីម៉ាប្រែទៅជាស្រឡាំងកាំងចំពោះអាកប្បកិរិយាមិត្ត។ នាងយកដៃអង្អែលលំអងតិចៗៈ

-ឯង...? ឯងយំរឿងអីលំអង? ជិតទៅផ្ទះវិញហើយឯងមិនសប្បាយចិត្តទេអ៊្ហា?

លំអងឆ្លើយទាំងយំអណ្ដើតអណ្ដកៈ

-ឌីម៉ា! ឯងដឹងហើយ! ពួកចោរវាចាប់គ្នាទៅ! ពេលលែងមកវិញវាលែងតែមនុស្ស របស់របរវាយកអស់ហើយ! លិខិតឆ្លងដែនគ្នាក៏....ក៏..

កេតឌីម៉ាធ្លាក់ថ្លើមក្ដុក។ នាងទើបតែយល់ថាលំអងខ្លាចដោយសារនាងគ្មានលទ្ធភាពជិះយន្តហោះត្រឡប់ទៅផ្ទះវិញបានក្នុងពេលនេះ ព្រោះនាងគ្មានលិខិតឆ្លងដែនក្នុងដៃ។

ស្រីស្រស់នៅស្ងៀមទ្រឹងចំពោះមុខស្ថានការណ៍ទាល់ច្រកដែលមិត្តក្លែងក្លាយកំពុងបង្កើតឡើងក្នុងចេតនាទុច្ចរិត។

ឃើញនាងចូលអន្ទាក់ខ្លួន លំអងធ្វើជាយំគគ្រូកស្ទុះមកឱបមិត្ត ៖

-ឌីម៉ា! ឯងកុំទៅណាចោលខ្ញុំណ៎ា កុំទៅ! ខ្ញុំគ្មានអ្នកណានៅទីនេះទេ! ខ្ញុំមានតែឯង!

ឌីម៉ាច្របូកច្របល់នាងនិយាយឡើងដោយភាពព្រួយបារម្ភអណ្ដែតពេញផ្ទៃមុខ៖

-យើងត្រូវតែប្ដឹងប៉ូលិស! យើងត្រូវឲ្យគេរកប៉ាស្ព័រឲ្យឯងវិញ ឬមួយរកមធ្យោបាយធ្វើថ្មីណ៎ា!

-ធ្វើគឺធ្វើហើយ! ប៉ុន្ដែមិនមែនបានភ្លាមទេ! ក្រែងឯងថាស្អែកលោកប្រុសរាមចេញពីទីនេះអ្វី? ចុះយើងបានអី? បើយើងមិនទៅតាមគេ អ្នកណាការពារយើង?

ឌីម៉ាឈ្ងោកមុខសញ្ជឹងគិត។ ស្ថានការណ៍អាក្រក់កាលពីព្រលប់ដែលនាងឃើញបន្ទប់ខ្លួនត្រូវរះកន្ទេស និងការចាប់ខ្លួនលំអងទៅសុទ្ធតែជាហេតុការណ៍មិនល្អគួរតែរិះគិត។ មុននេះ Kenធ្លាប់សន្និដ្ឋានថារាមនរិន្ទអាចនៅពីក្រោយរឿងនេះ។ ប្រសិនពិតមែន គឺគេធ្វើដើម្បីឲ្យនាងមករកគេតែប៉ុណ្ណោះ។ ចុះបើស្អែកនេះនាងនៅតែមិនទៅរកគេ ឬក៏ព្រមនៅឥណ្ឌូណេស៊ីបន្ដដើម្បីកំដរគេ តើគេនឹងធ្វើអ្វីទៀត?

-ឯងគិតអីឌីម៉ា? ឯងកុំគិតថានឹងឡើងយន្ដហោះទៅចោលគ្នាណ៎ា! កុំឲ្យសោះឌីម៉ា! គ្នាសូមអង្វរ!

ឌីម៉ាជ្រួញចិញ្ចើមដោយខ្វល់ខ្វាយ៖

-ឈប់ជ្រួលច្របល់ទៅលំអង! ឯងនេះ? គ្នាឯណាទៅចោលឯងកើត! គ្នាកំពុងគិតថាត្រូវធ្វើម៉េច!ហ៊ឹម!

លំអងបានដួចចិត្ត និយាយកាត់ផ្ងង៖

គិតអីទៀត? មានតែលោកប្រុសរាមទេដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការជួយពួកយើងទាំងប្ដឹង! ទាំងធ្វើប៉ាស្ព័រថ្មី! ទាំងការពារសុវត្ថិភាពពេលដែលយើងនៅរង់ចាំ! ឆាប់ទៅរកគេនិយាយគ្នាឲ្យច្បាស់ទៅ មិនបាច់គិតច្រើនទេ!

ឌីម៉ាដកដង្ហើមធំ៖

-ទោះអញ្ចឹងក៏ត្រូវចាំភ្លឺសិនដែរ! យប់កណ្ដាលអាធ្រាត្រហើយណ៎ានាង!

លំអងនៅតែមិនឈប់នាងពន្យល់បកវិញបន្ទាន់៖

-ចុះក្រែងឯងថាស្អែកគេត្រូវចេញទៅមែនទេ? ឯងចាំដល់ភ្លឺទើបនិយាយប្រាប់គេ មិនខ្លាចយឺតពេលទេ?

លំអងកាន់តែបង្ខំឌីម៉ាកាន់តែស្មុគស្មាញ។ នាងមួហ្មងក៏និយាយឡើងដោយទោសៈ៖

-ទោះយ៉ាងនោះក៏ឯងត្រូវទុកពេលឲ្យគ្នាបានគិតស្រួលបួលសិនដែរលំអង! ឯងក៏ដឹងដែរ គេជាប្រុសគេមិនមែន...គេមិនមែន..ខ្ញុំចង់និយាយថាគេមិនមែនត្រូវជាស្អីនឹងយើងផង យើងទៅរំខានគេម៉ោងថ្មីហ្នឹងកើតដែរ? រកវិធីផ្សេងទៅ!

លំអងមិនបង្អង់ទេ នាងប្រាប់ឪម៉ាវិញភ្លាម៖

-គេនៅមិនទាន់គេងទេ! ឯងមិនជឿមកតាមគ្នាមកឪម៉ា! មកមើលណេះ!

ឪម៉ាបើកភ្នែកធំៗនៅពេលដែលត្រូវលំអងទាញឲ្យក្រោកចេញពីគ្រែឆ្ពោះរានហាលខាងមុខបន្ទប់។ ពីកន្លែងរបស់នាងសម្លឹងទៅបន្ទប់បុរសត្រកូលខ្ពស់ នាងអាចមើលឃើញយ៉ាងច្បាស់នូវស្មាមាំទាំទាំងគូររបស់គេនៅលើបង្អែកសាឡុង។ ទោះបីគេអង្គុយបែរខ្នងប៉ុន្តែឪម៉ាអាចស្មានដឹងថាគេកំពុងធ្វើការជាមួយកុំព្យូទ័រសំណព្វរបស់គេ។

"ម៉ោង១ជាងហើយមិនទាន់សម្រាកទៀត? គេធ្វើអីហ្នបានជារវល់ម្លឹងៗ?"

សំឡេងលំអងលាន់មកតិចៗក្បែរត្រចៀក៖

-នែ៎ឈប់ឈរឆ្ងឹងអញ្ចឹងទៅ! ឱកាសមានហើយ! ធ្វើអីម្យ៉ាងទៅ!

នាងអូសដៃកេតឪម៉ាចូលក្នុងបន្ទប់រួច ស្រវាចាប់លើកទូរសព្ទលើតុរបស់សណ្ឋាគារមកបម្រុងប្រើតែត្រូវឪម៉ាពោលសួរទាំងភិតភ័យ៖

-ឯងគិតធ្វើអីហ្នឹងលំអង?

-កុម្ម៉ង់អីឲ្យឯងលើកយកទៅឲ្យគេញ៉ាំ!

ឪម៉ាទាញដៃលំអងឲ្យទម្លាក់ទូរសព្ទវិញ៖

-នែលំអង! ឯងឆ្កួតទេ? ម៉ោង១យប់ហើយ! បើម្នាក់នោះមិនយល់ថាយើងឡប់ ក៏ពួកចុងភៅដែលកំពុងដេកគេគិតថាយើងជាខ្មោចលងដែរ! ស្អែកព្រឹកទៅ! ច្រើនណាស់ក្រោកទៅពីព្រឹកបន្តិចទៅ!

លំអងនៅតែមិនព្រមដោយសារថានាងកំពុងអន្ទះសាចង់បានដំណឹងពីកន្លែងដែលរាមនរិន្ទកំពុងបម្រុងទៅដើម្បីផ្ញើដំណឹងទៅឲ្យ Kenដូច្នេះហើយទោះលំបាកយ៉ាងណានាងនៅតែព្យាយាម៖

-មិនបានទេឪម៉ា! គេមិនប្រាកដថាព្រមជួយយើងងាយៗទេ បើគេរវល់ច្រើនមឹងៗនោះ ពិសេសស្អែកឯងមានពេលឯណាលួងលោមគេឲ្យយល់ព្រម? នេះជាពេលល្អបំផុតហើយ! ឮអត់?

-ចុះឯងមានគិតពីខ្ញុំទេដែលឲ្យខ្ញុំគោះទ្វារចូលទៅរកគេថ្មើរណោះលំអង? អ្ហា?(ឌីម៉ាសួរទាំងទោមនស្ស)

លំអងជ្រប់មុខ។ នាងធ្វើជាកម្សត់ចង់ស្រក់ទឹកភ្នែកជាថ្មី។ យល់ថាមិត្តរន្ធត់ចិត្តភ័យពីសុវត្ថិភាពពេកបានជានាងធ្វើយ៉ាងនេះ ឌីម៉ាប្រឹងសង្កត់ចិត្តមកវិញ។ នាងនិយាយតិចៗទៅកាន់លំអង៖

-គ្នាគ្រាន់តែពិបាកប្រឈមមុខជាមួយគេ! ព្រោះគ្នានៅតែភ័យឯងយល់ចិត្តគ្នាផងលំអង!

លំអងតបវិញភ្លាម៖

-គ្នាដឹងហើយតែមុនគ្នាឲ្យឯងទៅក៏គ្នាគិតដែរ! លោកប្រុសរាមមិនមែនអាក្រក់ពេកទេ! ក្រែងឯងថាយប់មិញឯងដេកលក់ទល់ភ្លឺក៏គេមិនទាំងធ្វើអ្វីឯងផង! គេមានមុខមាត់ប៉ុណ្ណឹងៗដែរគេមិនមកបង្ខំចិត្តស្រីៗទេ! បើគេចង់ធ្វើអញ្ចឹងសន្និដ្ឋានថាឯងគេចបានដល់ពេលនេះអ្វី?

ឌីម៉ាដកដង្ហើមធំ នាងគិតម្នាក់ឯងស្ងាត់ៗថា ម៉េចបានជាលំអងទុកចិត្តបុរសនោះដល់ថ្នាក់ហ្នឹង។ តែដោយនិស្ស័យនាងជាមនុស្សត្រង់ នាងក៏បោះបង់ចោលចម្ងល់នោះវិញ។ ប៉ុន្តែលំអងឯណោះនាងក៏កំពុងគិតស្ងាត់ៗម្នាក់ឯងដែរថា កេតឌីម៉ាការពារខ្លួនមិនសូវហ៊ានទៅជួបរាម នរិន្ទគ្រាន់តែចង់រក្សាភាពស្អាតស្អំជូននាយKenតែប៉ុណ្ណោះ។

"បើនាងគិតថានាងនឹងបានបងKenនៅពេលចុងក្រោយនោះ នាងដេកយល់សប្តិទៅចុះស្រីល្ងង់"

គិតហើយលំអងងាកវាចាបន្ថែមមកកាន់នារីស្លូតត្រង់៖

-ឌីម៉ា! គ្នាចុះទៅក្រោមរកទឹកដោះគោក្តៅមួយកែវមកឲ្យឯង! ឯងលើកទៅឲ្យគេទៅណា៎!

ឌីម៉ាយល់នាងគ្មានផ្លូវគេចវេះទេ ម្ល៉ោះហើយក៏ងក់ក្បាលដោយដង្ហើមធំ។ លំអងបន្តមុនពេលចាកចេញ។

-រៀបចំខ្លួនឯងឲ្យស្រស់ស្រួលបួលទៅ! មកវិញឥឡូវហើយ!

ភាគទី១៨

នារីដ៏មានល្បិចបានឱកាសកាលណា ក៏ចាត់ចែងកុម្ម៉ង់បានទឹកដោះគោក្តៅមួយកែវហើយក៏រៀបចំខ្លួនឲ្យឌីម៉ាសមរម្យ រួចដើរទៅចុចទ្វារបន្ទប់បុរសមានអំណាចដែលនៅជាប់ខាងដោយអូសដៃនាំមិត្តនាងទៅជាមួយផង។

ចុចកណ្ដឹងរួចលំអងដាក់ថាសទឹកដោះគោលើដៃស្រស់ឱម៉ាដែលនៅឈរទ្រឹងដោយទឹកមុខស្លេក ហើយខ្លួននាងប្រញិបប្រញាប់រត់គេចចូលបន្ទប់វិញមុនពេលកំលោះអភិជនចេញមកឃើញ។

ទ្វាររបើកបង្ហាញទឹកមុខសស្លេករបស់នាងក្រមុំដែលប្រឹងញញឹមដាក់បុរសសង្ហា។ នាយជ្រួញចិញ្ចើមទាំងមាត់សើចស្វាគមន៍។ ទោះបីគេងយល់សុបិនក៏នាងមិនដែលគិតថាត្រូវចូលមករកបុរសម្នាក់នេះនៅម៉ោងមួយយប់ដែរ។

-សូមទោសដែលរំខានពេលលោកប្រុសរាមសម្រាក!

ពន្លឺភ្នែកមុតថ្លានៃបុរសសម្បុរស្រអែមស្រស់មិនមានបង្ហាញចេញនូវសញ្ញាងោកងុយបន្តិចណាសោះបានធ្វើឲ្យស្រីស្រស់នឹកងឿងឆ្ងល់ថាគេជាមនុស្សដែកឬអ្វី?

ជំនួសឲ្យចម្លើយ បុរសសង្ហាញញឹមហើយលូកដៃមកក្រៀកចង្កេះតូចតន់វិលត្រឡប់ចូលទៅក្នុងបន្ទប់ដោយរុញទ្វារបិទបន្សល់ឲ្យលំអងដែលពួនលបមើលពីចម្ងាយនូវស្នាមញញឹម និងសំណើចរីករាយក្នុងចិត្ត ″កេតឱម៉ា! ឯងជាសន្ទូចដែលល្អគ្រាន់បើ″។

មកដល់ទីដែលមានតែពីរនាក់ រាមនរិន្ទបែរមកចំពីមុខតរុណីហើយលើកដៃទាំងទ្វេក្រសោបចង្កេះនាងទាំងសងខាងព្រមជាមួយវាចាលែបខាយ៖

-នឹកខ្ញុំមែនទេកេតឱម៉ា?

ស្រីស្អាតទើសចិត្តនិម្មិតពួសម្ដីនេះ។ តាមចរិត នាងគួរតែឆ្លើយប្រាប់គេវិញថា ប្រុសៗស្លាប់អស់ក៏មិនទាន់ដល់វេននឹកគេដែរ ប៉ុន្តែនាងត្រូវទប់ចិត្តព្រោះតាមពិសោធន៍កាលពីល្ងាចដែលទើបមកដល់បាលី នាងដឹងហើយថារឹងរូសមិនអាចយកឈ្នះរាមនរិន្ទទេ តែបើលេងស្ទីលស្រីស្លូតប្រហែលជាបានផលជាង។

ស្រីស្អាតដែលនៅឈរទីទើរកណ្ដាលរាត្រីជាមួយកែវទឹកដោះគោលើដៃបានធ្វើឲ្យរាមនរិន្ទដឹងស្រេចហើយថានាងគ្មានពាក្យអ្វីសម្រាប់ឆ្លើយតបនឹងសម្ដីលែបខាយរបស់ខ្លួនឡើយ ម្ល៉ោះហើយនាយនិយាយបន្ថែម៖

-ល្អទេតើ! ខ្ញុំក៏កំពុងនឹកយើងដែរ!

គេលើកថាសទឹកដោះគោចេញពីដៃនាងទៅដាក់លើតុ រួចងាកមកក្រសោបខ្លួននាងសាជាថ្មី តែកេតឌីម៉ានាងមិនចង់ឲ្យគេយល់ខុសថានាងដែលចូលមករកគេថ្មើរណេះព្រោះរឿងផ្សេង តរុណីខំប្រឹងពន្យល់វិញ៖

-ឃើញលោកប្រុសរាមធ្វើការដល់ថ្មើរណេះបានជា...

រាមនរិន្ទងាកសម្លឹងកន្លែងដែលខ្លួនអង្គុយអម្បាញ់មិញ ហើយទើបតែចាប់អារម្មណ៍ដឹងថានារីបង្ហាញម៉ូត អាចសម្លឹងមកពីបន្ទប់នាងតាមរានហាលខាងមុខ ម្ល៉ោះហើយគេដើរទៅរុញទ្វារកញ្ចក់បិទមកវិញ ព្រមទាំងទាញវាំងននបាំងផង។

-លួចមើលបន្ទប់កូនកំឡោះគេ ដឹងថាត្រូវទទួលពិន័យអត់ស្រីស្អាត?

គេងាកមកវាចាឌីដងដាក់នារីដែលគេដឹងច្បាស់ថា យប់នេះនាងគ្មានផ្លូវទៅណារួចទេ ព្រោះថាគេនឹកនាងដល់ថ្នាក់ធ្មេចមិនលក់ទៅហើយ។ កាលដែលនរៈយើងមិនដាច់ចិត្តទៅរកនាងព្រោះចង់ទុកមុខឲ្យនាងចំពោះមុខមិត្តភ័ក្តិណាមួយតាំងពីល្ងាចមកឃើញ នាងកើតទុក្ខព្រួយរហូតផង នាយក៏គិតថាអាណិតនាងដែលល្ងើយដោយសារតែរឿងអ្នកដទៃ ដឹងអីនាងបង្ហាញខ្លួនវិញដូចក្នុងយល់សប្តិ បើនាយមិនចេះឆ្លៀតឱកាសមានតែចោលម្សៀតហើយ។ គិតឃើញតាមកំសួលចិត្តយុវវ័យរួចហើយរាមនរិន្ទប្រុងក្រសោបនាងជាលើកទី២ តែត្រូវនាងលើកកែវទឹកដោះគោហុចមកមុន។

ពន្លឺភ្នែកភ័យព្រួយរបស់នារីរូបល្អបង្ហាញចេញមកទន្ទឹមនឹងសម្តីល្ហួងលោម៖

- ពិសាទឹកដោះគោទៅ! ខ្ញុំធ្វើឲ្យលោកខានពិសាបាយល្ងាចដោយសាររឿងលំអង!

តាមចរិតប្រុសដើមទ្រូង៥ហត្ថ គេតែងចង់ឆ្លើយតបដោយវិជ្ជមាននូវរាល់សំណើរបស់ស្រីស្អាតដូច្នេះហើយបានជារាល់ពេលនាងសំណូមពរអ្វី គេមិនដែលដាច់ចិត្តបដិសេធនោះទេ។ លើកនេះក៏អញ្ចឹងដែរ រាមនរិន្ទលូកដៃទៅទទួលកែវទឹកដោះគោមកកាន់ តែបបូរមាត់ញញឹមដាក់ម្ចាស់កែវ៖

-គិតថាអត់មានជាតិងងុយ ជាតិអីទៅចុះណ៎ា!

ឌីម៉ាភ្ញាក់ព្រើតដោយអៀនខ្មាស។ បុរសនេះម្យ៉ាងដែរ ពេលធម្មតាដូចជាកាចណាស់ តែពេលខ្លះដូចជាទន់ភ្លន់មែនទែនហើយចិត្តទូលាយពេកផង បើគេដឹងហើយថាយើងបានដាក់ថ្នាំងងុយដេកម៉េចគេមិនដេញដោល ហើយឲ្យយើងរួចខ្លួនទទេៗ។ ឬមួយថាដូចបងKenនិយាយប្រាប់? គេធ្វើល្អចំពោះមុខយើង តែតាមពិតគេនៅពីក្រោយរឿងទាំងអស់? ហើយទីបំផុតយើងនៅតែត្រូវមករកគេវិញដោយខ្លួនឯង?

ធីតាថ្លោះទឹកមុខនៅពេលនឹកដល់រឿងនេះ។ ក្នុងមួយជីវិតនេះ នាងស្អប់បំផុត គឺស្អប់មនុស្សដែលប្រើល្បិចចំពោះមនុស្សដូចគ្នាហ្នឹងហើយ!

នៅពេលតរុណីទៅជាទោមនស្ស វង់ភក្រ្តបុរសអភិជនមិនចង់ឲ្យខូចបរិយាកាស នាយក៏លើកកែវទឹកដោះគោមកក្រេបក្អឹកអស់ក្នុងមួយដង្ហើម ធ្វើឲ្យឌីម៉ាតាមសម្លឹងដោយភ្ញាក់ផ្អើល។

-អស់ហើយ!

គេនិយាយដោយដាក់កែវចោលទៅលើតុធ្វើការ រួចងាកមករកស្រីស្រស់សាជាថ្មី។ ដៃម្ខាងក្រសោបលើចង្កេះ ដៃម្ខាងផាត់សក់នាងថ្នមៗ ខណៈដែលនាងកំពុងឈ្ងោកមុខ។ គេនិយាយផ្ទាញ់ផ្ទាលះ

-ឥឡូវគិតម៉េចទៀត?

កេតឌីម៉ាឆ្លេឆ្លានៅពេលដែលចំហាយក្ដៅអ៊ុនៗរសាត់មកប៉ះដង្ហើមនាង ហើយរាងកាយគេក៏ខិតចូលមកកាន់តែកៀកឡើងៗ។ នាងងើបមុខប្រទះឃើញទឹកមុខបុរសម្ចាស់បន្ទប់ប្រែប្រួលទៅជាក្រហមទោះបីគេប្រឹងរក្សាស្នាមញញឹម។

"បើឯងបណ្ដោយទៅតាមតណ្ហារបស់គេ ឯងចប់ហើយកេតឌីម៉ា! ឯងអាក្រក់បំផុតសម្រាប់បងKen ដែលខំបន្ទាបខ្លួនមកល្អស្មោះស្ម័គ្រនឹងឯង!"

សន្ទុះចិត្តស្នេហាចំពោះសុភាពបុរសក្លែងក្លាយKenធ្វើឲ្យនារីស្លូតត្រង់ក្លាហានហ៊ានមានៈរុញច្រានរាមនរិន្ទចេញអស់មួយទំហឹង ធ្វើឲ្យរាងកាយមាំទាំនោះទៅជាទ្រេតទ្រោតដោយសារនាយមិនគិតដល់ថាដំណាក់កាលនេះទៅហើយ នាងនៅតែអាចធ្វើយ៉ាងដូច្នេះ។

ដោយនឹកស្មានមិនដល់ថា ស្រីស្រស់ស្អាតដែលបានបង្ហាញខ្លួននៅពាក់កណ្ដាលអាធ្រាត្របែរជាមានអាកប្បកិរិយាឆ្មើងកន្ត្រើងដូចមនុស្សមិនដែលស្គាល់គ្នា និងមានប្រតិកម្មអវិជ្ជមានម៉្លឹងៗកំលោះអភិជនទៅជាភ័ន្តភាំង។ គេទប់ជំហរកុំឲ្យដួលបាន តែមិនអាចទប់ចិត្តងឿងឆ្ងល់នោះឡើយ។ នៅពេលភ្លើងតណ្ហានៅមិនទាន់រលត់បាន គេនៅតែចចេសចូលទៅរកនាងជាលើកទី២ដោយក្រសោបរាងកាយល្វតល្វៃនោះជាមួយកម្លាំងដៃដែលប្រាកដថានាងមិនអាចរើបម្រះទៀតបាន។

ស្រីស្រស់បារម្ភខ្លាចគេខឹងផង ភ័យពីសុវត្ថិភាពផង ធ្វើឲ្យអារម្មណ៍នាងទៅជាច្រាស់ច្រាល។ នាងព្យាយាមរុញទ្រូងរាមនរិន្ទចេញអស់មួយទំហឹង តែលើកនេះគេលែងរង្គើហើយ។

រាមនរិន្ទដែលស្មានថាសកម្មភាពកំណាញ់ខ្លួនដូចស្រីក្រមុំបរិសុទ្ធនេះកើតឡើង ដោយសារតែនាងនៅខឹងនិងខ្មាស ព្រោះខ្លួនបានបំភ្លេចនាងចោលយូរពេក ម្ល៉ោះហើយក្រៅពីមិនខ្វីប្រកាន់ច្រើន គេថែមទាំងយល់ថានេះជាពេលដែលត្រូវថ្នាក់ថ្នមចិត្តនាងតបស្នងរយៈពេលជាងបីខែបន្ទាប់ពីរាត្រីនោះ។

ដូចដែលកាលពីម្សិលអ្នកដឹងថានាងមានចេតនាប្រើជាតិងោកងុយនៅក្នុងការណាត់ជួបនៅ Amandari ប៉ុន្តែនាយនៅតែមិនប្រកាន់ខឹងដោយយល់ថា នាងមកជំនួសកំហុសស្ត្រីមេអណ្ដើកកុលាបដូច្នេះនាងភិតភ័យ និងចង់គេចវេះគឺជារឿងអាចអធ្យាស្រ័យតែអាកប្បកិរិយានោះ រឹងរឹតតែធ្វើឲ្យអ្នកប្រុសនឹកចង់ថ្នាក់ថ្នមប្រលោមបីនាងទ្វេឡើង។

ផ្ទុយស្រលះអ្វីដែលមនុស្សគិតតែមិនព្រមចេញមកតាមពិតមិនដូចទៅនឹងការស្មានរបស់អ្នកផ្សេងឡើយ។ រាមនរិន្ទចាប់ផ្ដើមដឹងបណ្ដើរៗថាខ្លួនស្មានខុសនៅពេលច្រមុះនាយប៉ះចំវត្ថុសើមដែលសម្រុកមកស្រោចស្រពលើរង់ភក្ត្រភ័យរន្ធត់ និងក្រៀមស្រពោន។

អ្នកចាប់អារម្មណ៍ថាជលនេត្រនោះលាយឡំជាមួយនឹងសព្ទសូរខ្សឹកខ្សួលផង។ គេបន្ធូរដៃខ្សាកហើយងើបមុខសម្លឹងនាងទាំងក្ដៅចិត្ត។ បបូរមាត់នាងនៅតែញ័រទទ្រើកដូចកាលពីថ្ងៃដំបូងដែលអ្នកបានជួបនាង ហើយសាជាថ្មីផ្ទៃមុខនាងបែរជាសស្លេក។

"ស្រីឆ្កួតនេះម៉េចក៏ពិបាកម្ល៉េះហ្ន៎? ចុះបើអញ្ចឹងនាងត្រដរចូលមកធ្វើអី?" គេគិតដោយសម្លឹងនាងចង់ឲ្យមុតធ្លុះដល់ចិត្តគំនិត។

ទោះបីមួហ្មង តែគេនៅតែទប់ចិត្ត។ សកម្មភាពកេតឌីម៉ាបានឆ្លើយនូវចម្លើយស្រេចហើយថា នាងមិនបានព្រមព្រៀងជាមួយស្នេហាបែបនេះ ហើយនាងក៏ទទួលបានជោគជ័យភ្លាមដែរដោយសាររាមនរិន្ទមិនធ្លាប់បង្ខំមនុស្សស្រីឲ្យលេងល្បែងស្នេហ៍ជាមួយខ្លួននៅពេលដែលគេមិនចង់ដែរ។

គេលែងដៃពីនាងខ្សាកនៅពេលដែលតណ្ហាចាប់ផ្ដើមរលត់ទៅ ជំនួសមកវិញនូវភាពមួហ្មង។ អ្នកប្រុសបែរខ្លួនចាកចេញទៅ ស្របពេលធីតាបែរខ្លួនយ៉ាងរហ័សតម្រង់មកទ្វារចេញ។

ទិសដៅបញ្ញាសត្តារបស់អ្នកទាំងពីរបានធ្វើឲ្យស្ថានភាពពណ៌ស៊ីជម្ពូក្នុងផ្ទៃបន្ទប់ប្រែទៅជារលាយខ្សុល។ ប៉ុន្តែវ៉ាលិសសម្លៀកបំពាក់របស់បុរសម្ចាស់បន្ទប់ដែលត្រូវបានរៀបរួចរាល់បញ្ឈរទុកនៅក្បែរទ្វារ បានធ្វើឲ្យនាងនឹកឃើញឡើងវិញនូវសម្ដីដែលខ្លួនសន្យាទាំងប៉ុន្មានមុននេះជាមួយលំអង។

នាងឈប់ង៉ក់ ហើយងាកក្រោយរឹង ប៉ុន្តែជើងដែលធ្វើតាមអារម្មណ៍ផ្លាស់ប្តូរ១៨០ដឺក្រេរបស់ម្ចាស់មិនអាចទប់ជំហរបានទេ វាបានបោកទៅប៉ះកូនវ៉ាលិសមួយទៀតនៅអមក្បែរនោះ ធ្វើឲ្យរាងកាយទាំងមូលត្រូវដួលបោកមកលើឥដ្ឋទាំងជំហរ។

ឪម៉ាខំទប់ខ្លួនក្រោកប៉ុន្តែកម្លាំងប៉ះទង្គិចខ្លាំងគួរសមធ្វើឲ្យនាងអាចមានលទ្ធភាពត្រឹមច្រត់ដៃក្រោកអង្គុយប៉ុណ្ណោះ។

រាមនរិន្ទបែរក្រោយសម្លឹងស្ថានភាពរបស់នាង។អស់ពីក្តៅចិត្តអ្នកប្រុសទៅជាអស់សំណើច។ គេដើរមួយៗមកអង្គុយមើលនាងនៅចំពោះកែវភ្នែកមូលក្លំដូចនិលច្នៃដែលស្រស់ស្រីកំពុងសម្លឹងមកដូចគ្នា។

-យើងរៀនក្បួនរញ៉េរញ៉ៃហ្នឹងពីសាលាណាមក?

ធីតាមិនចង់បន្តអង្គុយអញ្ចឹងនៅចំពោះមុខរាមនរិន្ទទេ នាងប្រឹងក្រោកជាលើកទី២ ប៉ុន្តែកជើងប្រែទៅជាចុកចាប់ខ្លាំងរហូតដល់ភ្លាត់មាត់អូយ។

រាមនរិន្ទឈប់សម្លឹងភ្នែកខ្មៅក្រឹបរបស់នាង គេងាកមកមើលកជើងដែលប្រែទៅជាហើមរលោង។ គេលូកដៃទៅត្រកងលើកនារីបង្ហាញម៉ូតទៅដាក់ឲ្យអង្គុយលើសាឡុងវិញដោយលែងចេញស្តី។

កែវទងវងតាមសម្លឹងសកម្មភាពបុរសអភិជនដែលកំពុងរើរកដបប្រេងតូចមួយចេញមកពីក្នុងកូនវ៉ាលិសចុងក្រោយ។ សកម្មភាពគេម៉ត់ចត់តែល្អិតល្អន់ខុសពីកាយវិការមុនៗដែលនាងបានឃើញ។ នាងទទួលស្គាល់ថាគេមិនដូចជាពួកជនអន្ធពាលចាប់ជំរិតមនុស្ស ឬដូចជាបុរសប្រើអំណាចដូចដែលបងKenរបស់នាងធ្លាប់និយាយជារឿយៗនោះទេ។

វិធីម៉ាស្សាលាបប្រេងរបស់គេ រឹតតែធ្វើឲ្យនាងចាប់អារម្មណ៍ថាគេមានកាយវិការទន់ភ្លន់និងថ្នាក់ថ្នមណាស់។ ដូចកាលពីរាត្រីដំបូងដែលនាងបានប្រគល់ទៅឲ្យគេ ជារាត្រីដែលនាងមានតែការឈឺចាប់ផ្លូវចិត្តប៉ុណ្ណោះ  ចំណែកល្បែងស្នេហារបស់បុរសត្រកូលអ្នកនយោបាយ នៅតែមានភាពទន់ភ្លន់ល្មមអាចចងចាំបាន។

នាងឈ្ងោកមុខហាក់ចាប់អារម្មណ៍ស្តាយក្រោយចំពោះភាពរញ៉េរញ៉ៃ និងគ្មានសណ្តាប់ធ្នាប់របស់ខ្លួន។

អាជ្រាត្រូវរំលងហួសទៅហើយ មិនត្រឹមតែចូលមកមិនឲ្យម្ចាស់បន្ទប់បានដេកពួនទេ ថែមទាំងនាំឲ្យគេមករវល់នឹងភាពសស្លើតសស្លក់របស់នាងផង។ នាងចង់ហារមាត់និយាយសុំទោសចំពោះបុរស

ដែលកំពុងតាំងខ្លួនជាគ្រូពេទ្យពិសេស ប៉ុន្តែដឹងខ្លួនបាននិយាយពាក្យនេះច្រើនដងហើយ បើសាមីខ្លួនគេមិនទ្រលាន់ នាងក៏គួរទ្រលាន់ខ្លួនឯងដែរ។

-ជើងនេះ ម៉េចក៏មួយអាទិត្យដែរបានអាចដើរបាន!

រាមនរិន្ទនិយាយដោយមិនងើបមុខសម្លឹងនាង។ នាងនៅស្ងៀមមិនស្តីអ្វីទៀតទេរហូតដល់ពេទ្យពិសេសចប់ការងារហើយចូលទៅបន្ទប់ទឹកសំអាតដៃ។ ក្រមុំរូបល្អឱនសម្លឹងជើងខ្លួនដែលសូម្បីលើកដាក់ទន្ទឹមគ្នាលើសាឡុងក៏សឹងថាពិបាក ទម្រាំដើរត្រឡប់ទៅបន្ទប់វិញ។

"កេតឌីម៉ា លំអងអត់មានលិខិតឆ្លងដែនវិលទៅប្រទេស ឯងក៏គ្រេចជើង ឯគេក៏ចេញពីបាលីស្អែកនេះហើយ ឯងគិតយ៉ាងម៉េចទៅ?"

ថ្មើរណេះលំអងប្រហែលគេងលក់ក្នុងក្តីសង្ឃឹមហើយ ប៉ុន្តែយើងជាមិត្តមិនទាន់បានធ្វើអីនៅឡើយទេ បានត្រឹមតែបន្ថែមនូវរបួសមួយពីលើស្ថានការណ៍ដែលកំពុងអាក្រក់ស្រាប់។

រាមនរិន្ទត្រឡប់មកវិញជាមួយសម្លៀកបំពាក់គេង។ គេញញឹមចំពោះកែវភ្នែកទើសទាល់របស់នាង។គេឱនត្រកងលើកកេតឌីម៉ាទៅសម្រាកលើគ្រែធ្វើឲ្យនាងកម្រើកគេចចេញហាក់ភ័យព្រួយតែក៏នៅតែគេចពីគេមិនរួច។

មកដល់លើគ្រែរាមនរិន្ទឈ្ងោកនិយាយតិចៗទល់នឹងកែវភ្នែកមូលក្លំរបស់នាង៖

-ម៉េចក៏ខ្លាចគ្នាដល់ថ្នាក់នេះឌីម៉ា?

ឃើញកែវភ្នែកបុរសបង្ហាញភាពអាក់អន់ចិត្តច្បាស់ក្រឡែត ទោះជាគេខំនិយាយស្តីបែបផ្ទូរស្រាលក៏នាងគួរតែខ្លាចចិត្តគេដែរ។ ប្រសិនបើរាមនរិន្ទពិតជាមនុស្សល្អតែពីមុខហើយមានល្បិចពិសពុលនៅពីក្រោយខ្នង នាងរឹតតែត្រូវដឹងខ្លួនហើយថា នាងមុខតែជួបរឿងថ្មីៗទៀតដែលពិបាកជាងនេះ។

មិនដឹងជាអ្វីបណ្តាលចិត្ត ស្រាប់តែតរុណីបន្លឺតិចៗទៅកាន់គេ៖

-លោកប្រុសរាម!...គឺ......គឺ...ខ្ញុំ....ខ្ញុំ...

រាមនរិន្ទឱនទល់មុខនឹងនាង ៖

-យ៉ាងម៉េច?

តរុណីនៅទីទើរក្រោមក្រសែភ្នែកស្រទន់របស់បុរសដែលនាងស្រាប់តែទទួលអារម្មណ៍ថាគេហាក់គ្មានត្រង់ណាបង្ហាញថាមានចរិតផ្ដាច់ការ និងកាចសាហាវដូចដែលនាងបានគិតរហូតមកសោះ។

មួយប៉ប្រិចភ្នែកដែលនាងនៅទីទើររាមនរិន្ទឈ្ងោកថើបបបូរមាត់ស្រស់ទងវងធ្វើឲ្យនាងទៅជាស្រឡាំងកាំងបន្តិចទម្រាំនឹកឃើញរុញគេចេញ។ កម្លាំងរុញច្រានដែលខ្សោយជាងមុននឹងបន្លាយពេលយូរយ៉ាងនេះបញ្ជាក់ឲ្យរាមនរិន្ទដឹងច្បាស់ថាលើកនេះនាងមិនប្រាកដជាបដិសេធទេ ប៉ុន្តែប្រហែលជានាងអៀនខ្មាសតាមធម្មជាតិរបស់នារីតែប៉ុណ្ណោះ។ គេនិយាយតិចៗចំពោះកែវភ្នែកភ័ន្តភាំងរបស់នារីបង្ហាញម៉ូតៈ

-មានអារម្មណ៍វិញខ្លះឬនៅ?

ឪម៉ាដឹងថាបើមិនធ្វើអ្វីម្យ៉ាងទេ គេនឹងបន្តអារម្មណ៍រវើរវាយទៅតាមបរិយាកាសអូសទាញហើយ។មាណវីប្រញាប់បន្តប្រយោគៈ

-...គឺ......គឺខ្ញុំ...ខ្ញុំ....ខ្ញុំ...នៅមិនទាន់ត្រៀមខ្លួននៅឡើយ!

បុរសសង្ហាម៉ិចភ្នែកសើចៈ

-ហើយចុះត្រូវការពេលប៉ុណ្ណាទៀតដើម្បីត្រៀមខ្លួន?

សំឡេងនរៈសង្ហាលាន់ឮមកនៅពេលនារីប្រឹងងាកគេចចេញហើយរាងកាយត្រូវគេឱបពីខាងក្រោយជាប់។

-ស្អែកនេះគ្នាទៅកន្លែងផ្សេងហើយ! យើងដាច់ចិត្តបែកគ្នាទាំងអញ្ចឹងមែនទេ?

តរុណីរូបល្អបើកភ្នែកមូលក្លំ។ ពិតមែនហើយ! ម៉េចក៏នាងមិនចាប់ផ្ដើមនិយាយនឹងគេពីបំណងរបស់លំអងក្នុងការឲ្យនាំពួកនាងជាមួយទៅ ក្រុងលោបានសម្រេច។

បរិយាកាសដូចជាមិនអាក្រក់រហូតដល់នាងត្រូវខូចបង់ផែនការនោះទេ។ នារីបញ្ឈប់ចលនាដែលចង់រុញដៃគេចេញ ហើយវាចាទៅកាន់នាយអភិជនដែលកំពុងសម្លឹងមកសរសៃសក់ទន់រលោងរបស់នាងដោយកែវភ្នែកអណ្ដែតអណ្ដូងៈ

-លោកប្រុសរាមត្រូវទៅកន្លែងណាទៀត?

គេមិនឆ្លើយបែរជាសួរវិញៈ

-ចុះអ្នកសួរហ្នឹងព្រមទៅជាមួយគ្នាអត់?

នាងទៅជាស្រឡាំងកាំងនៅពេលមិនទាន់បានសួរនាំផង គេបែរជាបង្អើបពីរឿងនេះមុនហើយងាយស្រួលម្លឹងៗ។ ប្រាណស្រីស្រស់ត្រូវគេលើកយកក្រសោបក្នុងប្រអប់ទ្រូងរឹងមាំរបស់គេ ហាក់រង់ចាំចម្លើយធ្វើឲ្យនាងងក់ក្បាលផ្ងក់ៗដោយមិនដឹងខ្លួន។ ចម្លើយវិជ្ជមានលឿនហួសពីការស្មានធ្វើឲ្យរាម នរិន្ទទៅជាងឿងឆ្ងល់។

"ហើយទៅបានការអី?បើទៅតាមធ្វើរញ៉េរញ៉ៃអត់បានអីដដែលហ្នឹង? "គេនឹកស្ងាត់ៗក្នុងចិត្ត"។

ភាគទី១៩

នរៈសង្ហាលូកដៃកាន់បាតដៃទន់ល្វៃរបស់នាង។ នារីរូបល្អវិញគិតថានាងអាចសុំទៅតាមរាម នរិន្ទមិនមែនជាការលំបាកទេ ប៉ុន្តែចុះករណីលំអង? ប្រសិនមិនសាកល្បងសំណូមពរគេឥឡូវ តើគួរចាំដល់ពេលណាទៀត? នាងដកអលជ្ជីចេញពីប្រអប់ដៃគេដោយពោលដល់សាច់រឿង៖

-ចុះតើលោកប្រុសឲ្យលំអងទៅជាមួយដែរទេ?

នារីប្រឹងញញឹមទាំងភ័យៗក្រោមក្រសែភ្នែកពិភាល់របស់រាមនរិន្ទ។ ស្រីៗមិនតិចនាក់ទេដែលគេបានជួបចុះម៉េចក៏មានមនុស្សស្រីចម្លែកអញ្ចឹងដែរ?

គេនៅស្ងៀមស្តាប់សម្តីនាង ប៉ុន្តែតាមពិតគេកំពុងងឿងឆ្ងល់ថានាងមានចេតនាអ្វីដែលនិយាយសុំបែបនេះ។ កេតឌីម៉ាបន្តភ្លាម៖

-លំអងបាត់Passportហើយ! គ្នានៅទីនេះតែឯងក៏មិនបានដែរ! លោកប្រុសរាមជួយយកអាសាផង!

អ្នកប្រុសទើបតែដឹងថាអញ្ចឹងហើយដែលនារីនេះសុខចិត្តចូលមករកអ្នកទាំងវេលាអាធ្រាត្រ។ តាមពិតនាងពូកែណាស់ រឿងពឹងពាក់នៅរាល់ពេលទាល់ច្រក ប៉ុន្តែនាងមិនដែលមានមនោសញ្ចេតនាស្មោះទេ តាំងពីគេស្គាល់នាងពេលណាគឺនាងមកបង្ហាញខ្លួនដើម្បីតែរឿងសាច់ញាតិ ឬមិត្តភ័ក្តិប៉ុណ្ណោះ។

ចិត្តទូលាយយ៉ាងណាក៏ចេះតូចចិត្តដែរ។ រាមនរិន្ទលូកដៃរកទូរសព្ទមកចុច ហើយឆ្លើយតបធ្វើហីមិនខ្វីមើលមុខនាង៖

-ហេតុអ្វីខ្ញុំត្រូវជួយស្រីម្នាក់នោះខ្ញុំ? អត់មានពេលច្រើនដើម្បីទៅរវល់រឿងអ្នកដៃទេ!

គឺគេបដិសេធច្បាស់ណាស់! (នារីចាប់ផ្ដើមឆ្ងល់ក្នុងចិត្តព្រោះនាងមិនដឹងទេថារាមនរិន្ទកំពុងផ្ចាញ់ផ្ចាលនាងប៉ុណ្ណោះ)។

បុរសលួចសម្លឹងនាង។ អ្នកក៏ប្រទះឃើញវង់ភក្ត្រដែលប្រែជាស្លេកស្លាំង និងអស់សង្ឃឹម។ អ្នកសើចតិចៗព្រោះដឹងថាកំពុងសងសឹកចរិតរញ៉េរញ៉ៃរបស់នាងបានដោយជោគជ័យ។ រាមនរិន្ទនិយាយតិចៗនៅពេលដែលស្រស់ស្រីឈប់និយាយស្ដី។

-តែខ្ញុំក៏អាចដូរចិត្តបើសិនពួកម៉ាករបស់ស្រីនោះ ឆ្លាតជាងមុនបន្តិច!

"ពួកម៉ាកស្រីនោះ"ដែលរាមនរិន្ទបង្អើប គឺរូបកេតឌីម៉ានេះហើយ។ ធីតាបង្ហាញម៉ូតនៅស្ងៀម ប៉ុន្តែនាងកំពុងបៀមជាប់នូវភាពហ្មងសៅ។

"ស្រីល្អលំអងអើយ! បើកុំតែឯង យើងក៏មិនយកមុខមកចោលឲ្យប្រុសម្នាក់នេះធ្វើបាបអញ្ចឹងដែរ! ចំណែកឯងដេកលក់ធ្វើហី! គ្មានបានមកជួយវេទនាអីជាមួយយើងទេ!"នាងគិតក្នុងចិត្ត។

បុរសលូកដៃចុចបិទភ្លើងធ្វើឲ្យមាណវីភ្ញាក់ព្រើត។ នាងងាកខ្លួនមើលថាតើគេបម្រុងធ្វើអ្វី ប៉ុន្តែសំណាងដែរដែលគេលែងទូរសព្ទពីដៃ ហើយលើកផាហ៊ុមដណ្ដប់អោយតរុណីដែលនៅស្ងៀមស្រពោនព្រោះមិនដូចបំណង។

ហាក់យល់ចិត្ត គេនិយាយតិចៗក្បែរសោតាះ

-គេងទៅ! យប់ណាស់ហើយប្រយ័ត្នជើងធ្វើទុក្ខ! ចំណែករឿងលំអងចង់ឲ្យទៅក៏បានតែ....ចាំណ៎ាទៅដល់Jayapuraទូទាត់គ្នាម្ដង!

ម្ដងនេះគេនៅតែជាសុភាពបុរស។ នៅពីក្រោយខ្នងនាងគេប្រហែលចាប់ផ្ដើមគេងហើយ ប៉ុន្តែកេតឌីម៉ានៅមិនទាន់ហ៊ានបិទភ្នែកសូម្បីតែមួយស្រឡេត។ បំណងការពារមិត្តពិតជាបានសម្រេចតាមការគ្រោងទុក ប៉ុន្តែបញ្ហាថ្មីគឺទីណាទៅចាយ៉ាពូរ៉ាJayapuraនោះ? ហេតុអីនាងត្រូវរសាត់អណ្ដែតតាមគេទៅដល់ទីនោះ ហើយយូរប៉ុណ្ណាទៅ?។

ធីតាសម្លឹងជើងខ្លួនឯងដែលគ្រេច រួចដៀងភ្នែកទៅរកបុរសដែលនៅពីក្រោយខ្នង ចំពេលសូរដង្ហើមរបស់គេបង្ហាញថាគេកំពុងលង់លក់ហើយនោះនាងគិតថាគេគ្រាន់បើដែរដែលមិនចេះបំពាននារីភេទនៅពេលនាងកំពុងមានរបួស។

**វគ្គទី១០**

ក្រុងចាយ៉ាពូរ៉ាJayapura

ដែនដីប៉ាពួថ្មីត្បិតថានៅឆ្ងាយដាច់សង្វែងនឹងបង្កប់ទុកនូវពាក្យចចាមអារ៉ាមជាច្រើនស្តីពីករណីរំលោភសិទ្ធិ ការចាប់ជំរិត និងភាពមិនស៊ីសង្វាក់គ្នារវាងកុលសម្ព័ន្ធជនជាតិដើមជាច្រើនអម្បូរប៉ុន្តែក្រុងធំJayapuraរបស់ខេត្តនេះ ពិតជាហ៊ឺហាមិនចាញ់សួគ៌ាទេសចរបាលីប៉ុន្មានឡើយ។

ទោះបីយ៉ាងនេះក៏ដោយ ក្នុងចំណោមនារីទាំងពីរគឺមានម្នាក់កំពុងត្រេកត្រអាលតែម្នាក់ទៀតកំពុងតានតឹងក្នុងចិត្តជាខ្លាំង។

លំអងនិយាយរកមិត្តទាំងមាត់នៅទំពាផ្លែប៉ោមញ៉ាចប់ៗ៖

-នែ៎ឪម៉ា! ឯងល្មមឈប់និយាយទូរសព្ទហើយ! គ្រាន់តែប្អូនមួយប៉ុណ្ណឹង និយាយផ្តាំផ្ញើឡើងទ្រលាន់ទៅហើយ! តិចឲ្យយកលុយទៅឲ្យ! តិចឲ្យខលទៅសួរ បើមានជីដូនមួយមើលហើយហ្នឹងនៅខ្វល់អីខ្វល់ម៉េះ? បើគ្នាជាមីងកុលាបវិញ គ្នាធុញស្លាប់ហើយ

ឪម៉ាចុចទូរសព្ទបិទហើយងាកមុខទាំងទឹកមុខស្មើះ

-បើមីងហ្នឹងហ៊ានធុញ ខ្ញុំនឹងឲ្យគាត់ដឹងរឿងមិនខាន! ដោយសារគាត់ហ្នឹងហើយបានជាគ្នាត្រូវនៅរញ៉េរញ៉ៃនៅទីនេះ!

លំអងដឹងថាឪម៉ាកំពុងខឹងចិត្តដែលមិនបានត្រឡប់ទៅ ស្រុកខ្មែរហើយបែរជារសាត់អណ្តែតមកដល់ឆ្ងាយយ៉ាងនេះ នាងមិនហ៊ានបន្តនិយាយផ្តេសផ្តាសទៀតទេបែរជាបត់ចូលដល់ផែនការសំងាត់របស់ខ្លួនវិញ។

-អ្ហ៎ឪម៉ា! ឯងឆ្ងល់អត់? ម៉េចក៏លោកប្រុសរាមមិនព្រមសម្រាកនៅអូតែល? គេមកជួលផ្ទះនៅឆ្ងាយពីក្រុងអីម៉េះ រកតែShoppingអីអត់បានសោះ!

ឪម៉ាធ្វើមុខក្រញូវដែលមិត្តភ្លេចរឿងទុក្ខបែរជាមានចិត្តស្វែងរករឿងត្រេកត្រអាលនាងបន្ទោសតិចៗ៖

-នៅសប្បាយទៅរួចទៀតលំអង?

នាងក្រោកក្រេសចាកចេញទៅរកសួនផ្កាដែលពុះច្រៀកផ្ទះឈើបុរាណជាពីរផ្នែកធំៗ។ នៅក្រោមជំនោរត្រសៀកដែលនាំមកនូវគន្ធពិដោរបុស្បាច្រើនបែប ឪម៉ាឈរមុខស្ងួតសម្លឹងទៅរកលំហាមេឃធំទូលាយ។ នាងដើរយឺតៗស្រូបយកអាកាសធាតុថ្មីក្នុងពេលដែលចិត្តនៅតឹងតែងណានឹកប្អូន

ណានឹកម្ចាស់ស្នេហ៍ដែលនៅឆ្ងាយ ណាខ្វល់ខ្វាយដោយសារតែពេលវេលាហាក់មានស្លាបហោះ។ តើយប់នេះ រាមនរិន្ទនឹងធ្វើបាបនាងដែរឬទេ បើនៅសុខៗនាងជាអ្នកចូលមករករូងខ្លាដោយខ្លួនឯងដូច្នេះ។

សំឡេងមួយលាន់ឮស្រាលៗ តែវាបានរសាត់តាមខ្យល់មកកាន់សោតាតរុណីម្តងខ្លាំងម្តងខ្សោយ៖

-ស្រីពីរនាក់នោះនឹងនាំបញ្ហាដល់ការងារយើងមិនខានទេលោកប្រុស។

ឌីម៉ាដៀងភ្នែកសញ្ជឹងគិតត្បិតថាសូរសព្ទនាងដូចជាប្រហាក់ប្រហែល ឯពាក្យលោកប្រុសចុងក្រោយប្រយោគប្រាកដជាសំដៅចំពោះរាមនរិន្ទច្បាស់ណាស់។

"ស្រីៗពីរនាក់ដែលគេទើបតែនិយាយ គឺយើងនិងលំអងមែនទេ?" នាងចាប់ស្លន់ស្លោ ក្នុងចិត្តហើយងាកភ្លែតទៅរកប្រភពនៃសូរសំឡេង។ ដូចរាល់ដង គឺនាងឃើញម្ចាស់ប្រុសនៃសំណាក់បុរាណនេះកំពុងកាន់កុំព្យូទ័រយួរដៃហើយធ្វើការដោយយកចិត្តទុកដាក់។ ចំណែកម្ចាស់សំឡេងអម្បាញ់មិញគឺបុរសអង្គរក្សមាឌស្រាវខ្ពស់ដែលនាងគិតថាមិនដែលធ្លាប់ឃើញគេពីមុនមកសោះ ម៉េចក៏សំឡេងគេដូចជាធ្លាប់ឮ។ នាងមិនចាប់អារម្មណ៍ទេថាសំឡេងនេះនាងបានឮច្រើនដងនៅពេលដែលនាងត្រូវថ្នាំសន្លប់គេងលក់នៅឯអាម៉ាន់ដារីនោះហើយ។

កំពុងវវឹកនាងស្រាប់តែឮបុរសនោះបន្លឺបន្ថែមទៅកាន់ម្ចាស់ប្រុសរបស់គេ៖

-ស្តាយណាស់ បើខ្ញុំមិនមកមុន កុំអីស្រីៗពីរនាក់ហ្នឹងមិនអាចមកតាមលោកប្រុសអញ្ចឹងបានទេ!គេមកតាមលោកប្រុសស្អិតម្លឹងៗ បើថាមិនមានបំណងអីក៏មិនកើតដែរ!

កេតឌីម៉ាភ័យក្តុកក្នុងចិត្ត។ នាងនឹកឃើញភ្លាមដល់នាយKenជាម្ចាស់ស្នេហ៍។ គេអត់នៅទីនេះទេ បើនាងមានរឿងអ្វី តើបានអ្នកណាជួយទៅ?

ស្រីស្អាតវេភ្នែកទៅរករាមនរិន្ទ ដែលពេលណាក៏មិនដែលកោងកាចដាក់នាងដែរ។ នាងសម្លឹងគេព្រោះចង់ដឹងថាគេមានប្រតិកម្មយ៉ាងណាចំពោះពាក្យចាក់រុករបស់មនុស្សក្រោមបង្គាប់។ ក្រសែភ្នែកដែលរេសន្សើមៗទៅរកបុរសមានអំណាចទាំងបេះដូងលោតញាប់ជាងមុន នាងក៏ឃើញគេងើបមុខចេញពីកុំព្យូទ័រហើយដៀងភ្នែកសម្លឹងកូនចៅ។ ពិតណាស់ថា កាយវិការនេះបង្ហាញពីការចាប់អារម្មណ៍របស់គេចំពោះសម្តីចាក់រុករបស់បុរសមាឌខ្ពស់ស្រាវ។ គេនៅមិនទាន់ស្តីថាយ៉ាងណានៅឡើយ ប៉ុន្តែកូនចៅគេនៅតែបន្ថែមទម្ងន់ស្ថានការណ៍៖

-លោកប្រុស! នៅសុខៗគេមិនមែនមកតាមតែម្នាក់ទេថែមទាំងមានគ្នាមកជាមួយ! ឥឡូវគ្នាយើងរាយការណ៍មកថាកូនឧកញ៉ា ឆាយ៉ាណគុណមកដល់ក្រុងចាយ៉ាពូរ៉ា Jayapura ដែរហើយ។ ខ្ញុំសុំទៅចាត់ការសួរចម្លើយស្រីៗនោះហើយលោកប្រុស! ពីរនាក់នោះជាមនុស្សបង្កប់ច្បាស់ណាស់ទាន! គឺពីរនាក់នោះលួចឲ្យដំណឹងទៅអ្នកប្រុសសិទ្ធិគុណបានជាពួកគេមកដល់នេះរហ័សម្លឹងៗ!

ឌីម៉ាភើតពោះដោយភ័យព្រួច។

"សិទ្ធិគុណមកដល់ក្រុងចាយ៉ាពូរ៉ាដែរ?" នាងក្រឡេកភ្នែកទៅរកបន្ទប់ខ្លួនដោយចង់រត់ទៅដល់ទីនោះក្នុងមួយដង្ហើមនេះដើម្បីប្រាប់លំអងនឹងអាលរកមធ្យោបាយរួមគ្នាដោះស្រាយស្ថានការណ៍។ តែភ្លាមនោះនាងឮសំឡេងមួយនិយាយកាត់ផ្ទួង៖

-ខ្ញុំអត់គិតអញ្ចឹងទេ!

ឌីម៉ាអរព្រើតព្រោះស្គាល់ថាជាសំឡេងនាយBird។ នាយអង្គរក្សម្នាក់នេះហាក់មានភាពសុភាពរាបសារដាក់នាងតាំងពីនៅបាលី។ ហើយគេបានអមដំណើររាមនរិន្ទនិងនាងជិះយន្តហោះមកកាន់ទីនេះ ដូច្នេះគេប្រាកដជាដឹងហើយថានាងមិនបានផ្តល់ដំណឹងឲ្យសិទ្ធិគុណដូចដែលបុរសអង្គរក្សថ្មីស្មាននោះទេ។

នាងនៅសម្ងំស្តាប់ពាក្យនាយBirdសឹងមិនហ៊ានទាំងដកដង្ហើម។ បុរសបង្កប់របស់នាយKen និយាយបន្ថែមដើម្បីការពារសមាសភាពកេតុឌីម៉ាក្នុងការសម្រេចគោលដៅធំរបស់គេ។ គេនិយាយ៖

-បងរឿន! បងធ្វើរឿងដូចស្មុគស្មាញពេកធ្វើអី? តាមពិតរឿងមកកាន់ក្រុងចាយ៉ាពូរ៉ាលាក់បានជិតស្អាតណាស់ សូម្បីតែខ្ញុំក៏មកតាមតែលោកប្រុសហៅគឺអត់ដឹងទៅណាមកណាទេ មានរឿងអីស្រីៗពីរនាក់នោះដឹងកើត?

តាមពិតឌីម៉ាទើបតែដឹងថាបុរសឈ្មោះរឿនដែលនាងបានដេកសន្លប់ហើយនៅចងចាំការសន្ទនារបស់គេបានតាមពិតគឺបុរសស្គមខ្ពស់នេះសោះ។ គេដូចជាកាចនឹងម៉ឺងម៉ាត់ណាស់បើប្រៀបជាមួយនាយBird។ នាងយល់ថាសំណាងដែរដែលនៅមាននាយBirdមួយដែលចេញមុខជួយការពារពួកនាង។ ខណៈកំពុងរិះគិត នាយរឿនតបទៅកាន់សហការីវិញភ្លាម៖

-អ្ហ៎! ហើយចុះរឿងដែលយើងនាំគ្នាមកកាន់ក្រុងនេះស្វាត់ដល់ម្លឹងម៉េចក៏ដឹងដល់កូនឧកញ៉ានោះកើត?

-កូនចៅបងរឿនឯងធ្លោយការណ៍ខ្លួនឯងក៏មិនដឹង? ម្យ៉ាងទៀត ពួកអ្នករកស៊ីភាគច្រើនគេចង់ដឹងដូចតែយើងដែរហ្នឹង! យើងចាប់អារម្មណ៍មកទីនេះរកផ្លូវរកស៊ី គេក៏អាចថាគិតដូចយើងដែរក៏ថាបាន!

នាយរឿនដែលមិនធ្លាប់ស្មានដល់ថានាយBirdជាជនបង្កប់ខ្លួននោះ គិតថានាយBirdក៏ប្រហែលជាមិនដឹងថារាមនរិន្ទមកកាន់ទីនេះដើម្បីឥន្ទបដិមាដ៏មានតម្លៃមហាសាលនោះដែរ ទើបគេធ្វើជានិយាយបង្វែងដានដើម្បីប្រកែកវិញភ្លាម៖

-វាមិនសមជួនគ្នាដល់ម្លឹងទេ! ចាយ៉ាពូរ៉ាឆ្ងាយផង ពិបាកធ្វើដំណើរផង គ្រោះថ្នាក់ផង បើគ្មានគោលដៅច្បាស់លាស់គ្មាននរណាមកទេ!

នាយBirdដឹងច្បាស់ថានាយរឿនមួហ្មងព្រោះខ្លួនមិនអាចធ្វើតាមបំណងរាមនរិន្ទដែលមិនចង់ឲ្យមានវត្តមានសេដ្ឋីខ្មែរណាម្នាក់នៅទីនេះក្នុងពិធីដេញថ្លៃឥន្ទបដិមាដែលគេល្បីតៗគ្នាជាច្រើនឆ្នាំមកហើយនោះឡើយ។ ដូច្នេះនៅពេលលេចវត្តមានក្រុមសិទ្ធិគុណនៅទីនេះដែរ គេស្រាប់តែបំបែរកំហឹងទៅរកនារីម៉ូដែលទាំងពីរដែលមកតាមបុរសមានអំណាច។ នាយBirdនិយាយធ្វើហី៖

-ត្រូវហើយ! បងរឿនឯងមានដឹងរឿងគេជិតដេញថ្លៃចម្លាក់ខ្មែរបុរាណមួយទេ?

នាយរឿនបើកភ្នែកធំៗដោយភ្ញាក់ផ្អើល ទន្ទឹមពេលដែលម្រាមដៃរាមនរិន្ទបញ្ឈប់ចលនានៅលើ Keyboard ។ប្រហែលជាអ្នកទាំងពីរគិតថាហេតុអ្វីបានជានាយBirdដឹងរឿងនេះហើយបានជាគេនាំគ្នាភ្ញាក់ផ្អើលដល់ម្លឹង ប៉ុន្តែនាយBirdនៅតែធ្វើដូចជាមិនដឹងរឿង។ នាយនោះនិយាយបន្ត៖

-លោកប្រុសរាម ឮសួរថាមានចម្លាក់ខ្មែរបុរាណមួយដែលរសាត់បាត់តាំងពីសម័យបារាំង ឥឡូវមានគេចង់បញ្ចេញវាមកដេញថ្លៃជាសាធារណៈ! ឧកញ៉ាសិទ្ធិគុណម៉ោប៉ាពួដោយសាររឿងនេះក៏មិនដឹង?លោកប្រុសរាម យើងគួរទៅមើលគេដេញថ្លៃដែរទេទាន?

កេតឌីម៉ាសម្លឹងទៅក្រសែភ្នែករាមនរិន្ទដែលរេចុះឡើងលើកុំព្យូទ័រ។ គេនៅតែដូចរាល់ដងអញ្ចឹងមិនងាយរំភើបមិនងាយមានប្រតិកម្ម។ ប៉ុន្តែនាយរឿន បែរជាច្រឡោតតោតតូង ស្ទុះទៅទាញកអាវនាយBirdច្រានចេញទាំងសម្តីក្រោធក្រេវ៖

-ចេញទៅធ្វើការងារឯងទៅ! កុំមកចេះដឹងរឿងចៅហ្វាយ! ២០ម៉ែត្រជុំវិញបរិវេណសួននេះ តែរុយមួយក៏មិនត្រូវឲ្យហើរចូលមកបានដែរឮទេ?

នាយBirdដឹងថា ការដែលពិធីដេញថ្លៃឥន្ទបដិមាត្រូវបែកការបានធ្វើឲ្យរាមនរិន្ទខកចិត្តយ៉ាងខ្លាំង ហើយនាយរឿនក៏មានអារម្មណ៍ថាខ្លួនមិនបានការដែរ ដូច្នេះហើយបានជាគេកាន់តែបង្កើនការយាមកាមសន្តិសុខចៅហ្វាយប្រុសរបស់គេទ្វេឡើង។

នាយអង្គរក្សបង្កប់ខ្លួន ងាកខ្លួនបម្រុងចាកចេញតាមការបណ្ដេញរបស់ថ្នាក់លើទៅហើយស្រាប់នាយរឿនស្រែកកាត់៖

-ឈប់សិន!

ពេលនាយBirdងាកមកវិញនាយរឿនគំហកបន្ថែម៖

-មើលស្រីម៉ូដែលពីរនាក់ហ្នឹងឲ្យជាប់ផង! ឃើញអីប្លែកឆាប់រាយការណ៍ភ្លាម ឮទេ?

នាយBirdងៀងភ្នែកមើលរាមនរិន្ទបន្តិចមុនពេលឆ្លើយបាទនឹងសម្ដីនាយរឿនហើយចាកចេញទៅ។ នារីបង្ហាញម៉ូតដែលឈរញ័ររពោះនៅឯសួនផ្កាខ្លាចថាត្រូវបានក្រុមអង្គរក្សឃើញនោះប្រវេប្រវាដើរត្រឡប់ក្រោយឆ្ពោះទៅរកទីសំណាក់របស់ខ្លួនវិញទាំងព្រលឹងចុងសក់។ មកដល់ក្នុងបន្ទប់ដែលមិត្តនារីខ្លួនកំពុងឈរតុបតែងខ្លួននៅនឹងមុខទូសំអាង ឌីម៉ាស្រវាបិទទ្វាររួចស្ទុះទៅពោលតិចៗដាក់លំអងទាំងស្លឹតស្លក់៖

-រឿងធំហើយនាង!

លំអងញាក់ចិញ្ចើមដោយទឹកមុខនឹងថ្កល់៖

-រឿងអីធំដល់ថ្នាក់ធ្វើឲ្យស្រីស្នេហ៍លោកប្រុសរាមភ័យដល់ថ្នាក់នេះ?

កេតឌីម៉ានិយាយទៅកាន់លំអងទាំងទឹកមុខស្លេកភ័យ៖

-ឯងដឹងទេ ម្នាក់អីដែលឈ្មោះសិទ្ធិគុណក៏មកទីនេះដែរ! គឺគេមកចាយ៉ាពូរ៉ានេះដែរណ៎ា!

លំអងបញ្ឈប់ចលនាលាបក្រែម ហើយបែរសន្សឹមៗមករកមិត្តនាងមិនទាន់និយាយអ្វីមែន ប៉ុន្តែតាមពិតនាងកំពុងភ្ញាក់ផ្អើល។ អារម្មណ៍នារីមានកល វិលខ្វាល់ជុំវិញសំនួរថា "យើងឲ្យដំណឹងតែបងKenទេចុះម៉េចក៏អាគាត់សិទ្ធិគុណនោះដឹងដែរ? ហើយមកដល់បានលឿនជាងបងKen ម្ល៉េះ???"

ឃើញភាពភ្ញាក់ផ្អើលរបស់លំអង ឌីម៉ាកាន់តែភ័យ នាងនិយាយបន្ថែមស្រាលៗខ្លាចមានគេឮ៖

-លំអង! គិតយ៉ាងមេចទៅ? គេ...គេ...គេកំពុងតែសង្ស័យថាយើងជាមនុស្សបង្កប់!

សម្ដីចុងក្រោយនេះធ្វើឲ្យលំអងភ្ញាក់ស្ទើររបូតគ្រឿងសំអាងពីដៃនាងងាកមកសម្លឹងឪម៉ាយ៉ាងមុតដើម្បីឲ្យច្បាស់ថានាងនិយាយមែនឬក៏លេង។ តាមពិតអ្នកដែលត្រូវភ័យខ្លួនបំផុតក្នុងពេលនេះមិនមែននារីស្លូតត្រង់ចាញ់បញ្ឆោតគេទេ តែគឺនារីសម្បុរល្បិចលំអងទៅវិញព្រោះពេលដល់ព្រលានយន្តហោះកាលណា នាងបានដឹងជាស្រេចពីគោលដៅដែលរាមនរិន្ទកំពុងទៅ ដូច្នេះនាងបានផ្ញើសារទៅឲ្យគូកំណាន់ គឺនាយKenបាត់ទៅហើយ។ នៅពេលនេះឮមិត្តបង្ហើបថាម្ចាស់សំណាក់កំពុងសង្ស័យថាខ្លួនជាមនុស្សបង្កប់ នាងត្រូវទន់ដៃជើងតែម្ដង ព្រោះថាទោះស្រមៃក៏នាយKenមិនអាចជិះយន្តហោះមកជួយពួកនាងទាន់ពេលដែរ។

-ឯង....ឯងនិយាយអីហ្នឹងឪម៉ា?

ឪម៉ាឆ្លើយដោយទឹកមុខតានតឹង៖

-នៅសួនច្បារ កូនចៅគេកំពុងទូលពិតគេ! គេថា គេថាយើងជាមនុស្សរនុកក្នុងរាយការណ៍ពីរឿងផុនគេប្រាប់សិទ្ធិគុណ!

លំអងសួរវិញភ្លាម៖

និយាយឲ្យវាស្រួលសិនមើល៍! អ្នកណានិយាយប្រាប់អ្នកណា?

ឪម៉ាដាក់បង្គុយប៉ុកទៅលើពូក ហើយប្រញាប់ឆ្លើយទាំងភ័យព្រួយ៖

-អង្គរក្សគេឈ្មោះរឿន! ម្នាក់ហ្នឹងដូចជាកាចណាស់! គេនិយាយថាឧកញ៉ាសិទ្ធិគុណមកដល់ចាយ៉ាពូវ៉ាហើយ ហើយគេប្រាប់លោកប្រុសរាមថា ពីរនាក់យើងគួរឲ្យសង្ស័យបំផុត ថាជាមនុស្សបង្កប់!

លំអងធ្លាក់ថ្លើមក្តុក។ នាងកំពុងគិតថា ឬមួយក៏សកម្មភាពដែលនាងនៅព្រលានយន្តហោះលួចរាយការណ៍សម្ងាត់ប្រាប់ទៅ Kenត្រូវគេដឹងអស់ហើយ? ចុះម៉េចក៏លេចចេញសិទ្ធិគុណពីណាមកទៀត? ប៉ុន្តែនារីមានល្បិចនៅតែតាំងចិត្តបានរឹងមាំហើយធ្វើជាសួរបកទៅកាន់កេតឪម៉ាវិញ៖

-ចុះឯងមានបានធ្វើអញ្ចឹងដែរអត់?

កេតឪម៉ាវេភ្នែកគិតដោយពិបាកចិត្ត។ តាមពិតពីមុនគឺនាងពិតជាមនុស្សដែលKenឲ្យមកបង្កប់ជាមួយរាមនរិន្ទមែន ប៉ុន្តែមិនមែនពេលនេះទេ ហើយនាងក៏មិនដែលទៅរាយការណ៍ប្រាប់អ្នកណាពីដំណើររាមនរិន្ទដែរ សូម្បីតែKenព្រោះនាងមិនដែលខ្វល់ថាគេទៅណាមកណា ហើយសំខាន់ ឬ

អត់នោះឡើយ។ ពេលនេះនាងមកចាយាពូរ៉ាតាមគេដោយសារតែជួយលំអងប៉ុណ្ណោះ។ ដល់ពេលត្រូវមិត្តសួរបញ្ជាក់អញ្ចឹងនាងគ្រវីក្បាលបដិសេធភ្លាម។

-ឯងនិយាយឆ្កួតអីហ្នឹងលំអង?

លំអងនិយាយវិញរ៉ាវ៖

-បើអត់ទេឯងភ័យធ្វើអី?

ភាគទី២០

ទឹកមុខឌីម៉ានៅតែមិនសុខមិនសាប់ នាងនិយាយតបវិញភ្លាម៖

-មិនឲ្យភ័យកើតដែរ! បើគេកំពុងតែនិយាយអាក្រក់ពីយើងនៅនឹងមុខចៅហ្វាយគេ!

លំអងនិយាយដោយដើរមកអង្គុយក្បែរមិត្ត នាងបញ្ចេញវិធីពន្យុះកេតឌីម៉ា៖

-ចុះលោកប្រុសរាមជឿទេ!

ឌីម៉ារំលឹកនឹកទៅដល់ទឹកមុខរាមនរិន្ទកាលពីពេលដែលនាយរឿនហារមាត់និយាយពីគំនិតសង្ស័យរបស់គេ។ នាងក៏មិនឃើញបុរសមានអំណាចមានប្រតិកម្មអ្វីគួរឲ្យកត់សម្គាល់ដែរ ប៉ុន្តែគេតែងតែនៅស្ងៀមមិននិយាយស្ដីអញ្ចឹង តើឲ្យនាងស្ងប់ចិត្តម៉េចនឹងកើតទៅ? នាងឆ្លើយតបវិញជាមួយលំអង៖

-អត់ដឹងទេ! ឃើញគេស្ដាប់កូនចៅគេនិយាយហើយគេក៏នៅស្ងៀម!

លំអងបានដៃក៏និយាយបន្ថែម៖

-អញ្ចឹងមានអីត្រូវព្រួយ! បើគេគ្មានប្រតិកម្ម មានន័យថាគេមិនខ្វល់ពាក្យអស់ហ្នឹងទៅហើយ! នែ៎ឌីម៉ា ឲ្យក្លាហានរឹងមាំឡើង កុំអីបន្តិចភ័យ អីបន្តិចភ័យ! ពួកនោះជាបរិវារ តែឯងជាស្រីស្នេហ៍របស់គេ!

ឌីម៉ាបើកភ្នែកធំងាកសម្លឹងមិត្ត នាងនិយាយកាត់តិចៗទាំងទើសទាល់៖

-លំអងឯងកុំនិយាយអាក្រក់ស្ដាប់ពេកមើល៍!

លំអងនៅតែជម្នះនិយាយ៖

-មិនមែនឯងត្រូវខ្លាចចិត្តពួកហ្នឹងទេ តែគឺពួកហ្នឹងទេដែលត្រូវក្រែងចិត្តឯង! ទៅនៅទីនេះធ្វើអីទៀត?

ឱម៉ាបើកភ្នែកមូលក្រឡង់ដោយងឿងឆ្ងល់៖

-ឯងឲ្យយើងទៅណាលំអង?

នារីមានឧបាយនិយាយសង្វើញមិត្តភ័ក្តិ៖

-ចេញទៅរកគេទៅ! បើឯងចង់ឲ្យខ្លួនសុខ គឺត្រូវតែនៅជិតគេគ្រប់ពេលនៅរហូតដល់អ្នកផ្សេងគេគ្មានសិទ្ធិចូលមកជ្រៀតជ្រែកបំបែកបំបាក់ឯងបានណ៎ា! ឯងឮគេនិយាយអាក្រក់ពីឯងមិនគិតចូលទៅតវ៉ាគិតពីរត់ចេញមកភ័យ! ហ្នឹងគឺឯងទុកឱកាសឲ្យគេបានវាយប្រហារឯងទេតើ! តោះៗទៅភ្លាមទៅ! ទៅនៅជិតលោកប្រុសរាមតែម្តង ចាំមើលតើពីណាគេហ៊ានថាអីឲ្យឯងទៀត?

ឱម៉ាងាកមុខចេញដោយទឹកមុខស្លន់ស្លោ៖

-ឯងឆ្កួតហើយ! ធ្វើអីកុំឲ្យជ្រុលពេកណ៎ា! គ្នាមិនទៅទេលំអង! វីវរហើយយើងត្រូវនាំគ្នាត្រឡប់ទៅវិញ! គ្នាចង់ចេញពីកន្លែងនេះ!

ធីតាស្លូតត្រង់មិនយល់ទេថា តាមពិតលំអងក៏កំពុងស្លន់ស្លោដែរក្នុងការទទួលបានព័ត៌មានថ្មីនេះ។ ក្រៅពីចង់ប្រាប់ដំណឹងទៅសង្សារថាសិទ្ធិគុណក៏កំពុងបង្ហាញខ្លួននៅទីនេះដែរនោះ នាងរឹតតែចង់ឲ្យឱម៉ាចេញទៅបាត់ដើម្បីនាងបានឱកាសទាក់ទងតាមទូរសព្ទទៅសួរយោបល់Kenបន្ថែមនៅពេលស្ថានការណ៍ប្រែប្រួលរហ័សយ៉ាងនេះ។ នាងគិតថាប្រសិនបើរាមនរិន្ទ និងបក្សពួកពិតជាសង្ស័យមែននាងគួររកមធ្យោបាយបង្ការជើងព្រួលឲ្យហើយ។ នាងអាចរើសយកមួយរវាងការគេចយករួចខ្លួន ឬមួយរកអ្នកទទួលកំហុសជំនួស។ ការបណ្តេញឱម៉ាឲ្យទៅរករាមនរិន្ទគឺដើម្បីឲ្យនាងទៅស៊ើបពីចិត្តរាមនរិន្ទឲ្យបានច្បាស់ផងថាគេពិតជាជឿតាមសម្តីកូនចៅ ឬមួយយ៉ាងណា? ទី២ នាងក៏បានឱកាសស្ងាត់ដើម្បីទាក់ទងទៅ Kenផង។

នៅពេលឃើញឱម៉ាភ័យដល់ថ្នាក់នេះនាងរឹតតែមួហ្មងប៉ុន្តែនាងចង់សម្រេចការធំត្រូវតែទប់ចិត្តមកពន្យល់លួងលោមតិចៗវិញ។

-ឱម៉ា! ឯងកុំគិតអីអាក្រក់ពេកមើល៍! លោកប្រុសរាមស្រលាញ់ឯងម្លឹងៗ! គ្មានអ្នកណាអាចធ្វើបាបឯងបានទេ! មើលជើងឯងចុះ! តាមពិតមួយអាទិត្យទៀតក៏ដើរមិនបានផងតែក្រមួនឆ្អឹងដំរីរបស់ជន

ជាតិចាវាដែលថ្លៃរាប់ពាន់ដុល្លារ គេក៏ចំណាយទិញមកឲ្យឯងលាបរបួសបើមិនមានចិត្តលើឯង គេមកខ្វល់ខ្វាយឯងអីដល់ម្លឹង?

នារីអ្នកបង្ហាញម៉ូតងាកមុខមករកមិត្ត។នាងបង្ហាញភាពភ័យព្រួយយ៉ាងជ្រាលជ្រៅតាមពន្លឺភ្នែកហាក់ចង់ឲ្យមិត្តយល់ចិត្តខ្លួនថាកំពុងពិបាកចិត្តកម្រិតណា។ អស់បន្តិចទើបនាងនិយាយចេញមករួច៖

-លំអង! គេហ្នឹងអ្វីដែលមកស្រលាញ់យើង? ឯងកុំស្រមៃកណ្ដាលថ្ងៃ ហើយកុំបានចិត្តទៅបង្ករឿងពេកណ៎ា អង្គរក្សគេឈ្មោះរឿននោះ កាចណាស់ បើមានរឿង យើងយ៉ាប់ហើយ!

លំអងកាន់តែរំកិលមកកៀកនឹងមិត្ត។ នាងពោលលួងលោមភ្លាមដោយមិនរវល់ពីអារម្មណ៍កេតឌីម៉ា៖

-ឌីម៉ា! បើគេមិនស្រលាញ់ឯង គេមិនមែននាំឯងមកដល់ទីនេះទេ? កូនអ្នកតំណាងរាស្ត្រមួយទាំងមូល គេតក្រុកនាំឯងទៅរកគ្នាដល់ឆ្នេរ ព្រោះតែឯងយំរហែមរហាមខ្លាចគ្នាត្រូវពួកចោរធ្វើបាបឥឡូវគ្រាន់តែឯងសុំមួយម៉ាត់ពីរគេសណ្ដោងឯងនឹងគ្នាមកដល់ចាយ៉ាពូរ៉ា! អង្គរក្សសំគិះនោះកាចក៏កាចទៅ បើគ្រាន់បើកុំមកធ្វើបរិវារគេ! គេប្រហែលជាមានប្អូនស្រីបានជាចង់ហួងហែងលោកប្រុសរាមទុក ឯងកុំចូលអន្ទាក់គេ ត្រូវក្លាហានឡើងដើម្បីស្នេហារបស់ពួកឯងណ៎ាកេតឌីមា!

កាន់តែស្ដាប់កាន់តែវិលវល់ នារីរូបល្អជ្រួញចិញ្ចើមតបតវិញទាំងសុញគំនិត៖

-លោកយាយ! ឈប់រវើរវាយទៅ! ស្នេហាអី? យើងនឹងគេហ្នឹងហី? ឯងគិតទៅរួចនាងនេះ? មួយទៀតអារឿងគេនាំខ្ញុំទៅរកឯងដល់ឆ្នេរនោះមិនមែនមកពីគេបារម្ភយើងទេ ជួនកាលគេអាចជាអ្នកនៅពីក្រោយរឿងចាប់ជំរិតឯងផងក៏មិនដឹង កុំសប្បាយភ្លេចខ្លួនពេក! ឃើញគេមាន ឃើញគេខ្ពស់ឯងងប់នឹងអំណាចគេ ទុកចិត្តគេដល់ម្លឹង? កោតណាស់ឯងនេះ?

លំអងយល់ហើយថាដោយសារល្បិចរបស់Kenទើបបានជាស្រស់ស្រីឌីម៉ាដែលស្លូតត្រង់បែរជាយល់ខុសថាត្រូវយល់ខ្មៅថាស រហូតដល់មើលមិនឃើញទាំងអំពើល្អរបស់បុរសឋានៈខ្ពស់ដែលតែងតែសន្ដានចិត្តឲ្យនាងរហូតមក។ លំអងកាន់តែមានអារម្មណ៍ថានាយKenសំណព្វរបស់នាងពិតជាមានមន្តស្នេហ៍មិនធម្មតាមែនក្នុងការអាចធ្វើឲ្យកេតឌីម៉ានៅជិតបុរសប្រហែលរាមនរិន្ទហើយនៅតែមិនលង់ស្នេហ៍នាយបាន ព្រោះធីតាបានជាប់ជំពាក់ចិត្តក្នុងល្បិចពិសពុលស្នេហ៍របស់បុរសកំពូលល្បិចកលទៅហើយ។

នាងធ្វើជាដៀងភ្នែក សួរមិត្តហាក់មិនយល់ការណ៍៖

-ម៉េចបានជាឯងគិតថាលោកប្រុសរាមបញ្ជាឲ្យគេចាប់គ្នា? ឯងចង់ថាគេប្រើល្បិចនេះដើម្បីកុំឲ្យឯងចេញទៅកម្ពុជាវិញមែនទេ?

ឌីម៉ាដែលនៅតឹងទ្រូងដោយស្ថានការណ៍ដែលនាងលួចស្ដាប់ឮនៅឯសួនផ្កានោះមិនអាចរកពាក្យអ្វីមកនិយាយបន្ថែមទេ ស្រាប់តែស្នូរគោះទ្វារតុៗលាន់មកកាត់ផ្ដាច់ចង្វាក់សន្ទនារបស់នារីទាំងទ្វេធ្វើឲ្យពួកគេងាកទៅរកទ្វារទាំងភ្នែកគ្រលួង។

លំអងងាកមកមើលធីតាជាមិត្តដែលកំពុងស្លេកស្លាំង នាងនិយាយតិចៗ៖

-ចាំគ្នាទៅមើល!

លំអងមួលសោបើកទ្វារ។ ទោះព័ត៌មានពីសកម្មភាពសង្ស័យរបស់អង្គរក្សរឿនធ្វើឲ្យនាងភ័យព្រួយខ្លះៗពីសមាសភាពខ្លួនថាអាចត្រូវបានបែកធ្លាយ ប៉ុន្តែសារជាតិជាមនុស្សមានកលច្រើន  នាងអាចទប់ចិត្តឲ្យនឹងនបានល្អជាងនារីស្លូតត្រង់ដូចកេតឌីម៉ា។

ម្យ៉ាងនាងនៅតែមានជំនឿថារាមនរិន្ទពិតជាមានចិត្តឲ្យកេតឌីម៉ាច្បាស់ណាស់ ចង់មិនចង់គេមិនងាយនឹងធ្វើបាបនាងនោះឡើយ។ យល់ដូច្នេះហើយបានជានាងនៅតែងងើលបន្តចាំមើលស្ថានការណ៍ចំពោះមុខ។

រូបរាងអង្គរក្សBirdបង្ហាញខ្លួននៅមាត់ទ្វារធ្វើឲ្យលំអងធូរទ្រូងខ្សាកវិញ ហោចណាស់នាងមានគ្នីគ្នាម្នាក់ទៀតដែរនៅទីនេះ។នារីមានល្បិច និងបុរសអង្គរក្សបង្កប់ខ្លួននៅតែសម្ដែងល្ខោនធ្វើជាមិនស្គាល់គ្នា ដោយនាយBirdឱនកាយគោរពមុននាំពាក្យមកប្រាប់៖

-លោកប្រុសរាមឲ្យអញ្ជើញអ្នកនាងឌីម៉ា!

លំអងរវេភ្នែកសម្លឹងនាយBirdជាសញ្ញាសួរថាមានរឿងអ្វីអត់? បុរសនោះព្រិចភ្នែកវិញជាសញ្ញាថាស្ថានការណ៍នៅអាចគ្រប់គ្រងបាន ធ្វើឲ្យនារីទ្រុស្ដមិត្តហាក់មានកម្លាំងចិត្តជាងមុន។ នាងបែរក្រោយសម្លឹងកេតឌីម៉ាដែលមុខសស្លាំងដូចក្រដាសរួចទើបងាកទៅតបបែបនឹងធឹងទៅកាន់នាងអង្គរក្សវិញ។

-សុំពេលរៀបចំខ្លួនសិនណ៎ា! ឌីម៉ាទៅតាមក្រោយឥឡូវហើយ!

នាងបិទទ្វារទៅវិញក្រោយពេលនាយBirdឱនគោរពរួចចាកចេញ។ឪម៉ាឆ្លេឆ្លាសម្លឹងលំអងធ្វើឲ្យនារីមានល្បិចសើចខឹករបៀបហួសចិត្ត។

-នាងអើយនាង! ឯងមិនមែនក្មេងអាយុ៧ឆ្នាំទេណា៎! គ្រាន់តែមើលក៏ដឹងថាប្រុសនោះគេស្រលាញ់ឯងគេត្រូវការឯងឲ្យនៅជិតគេដែរ! ទៅៗលឿនឡើង!

ឪម៉ាដែលមិនព្រមទទួលយកការវាយតម្លៃស្ថានការណ៍បែបសាមញ្ញរបស់លំអងនោះ បែរជានិយាយកាត់វិញភ្លាម៖

-តែឯងគិតមើល៍! អង្គរក្សគេទើបតែនិយាយអាក្រក់ពីយើងស្រាប់តែឥឡូវគេឲ្យនាយ Birdមករកគ្នា?

-គឺគេមិនជឿអង្គរក្សមាត់កំភ្លាញនោះហើយគេនឹកឯងចង់ឃើញឯងហ្នឹងណា៎ស្រីល្ងង់?

ទោះយ៉ាងណានៅទីបំផុតលំអងនៅតែអាចបង្ខំឲ្យកេតឪម៉ារៀបចំខ្លួននឹងចេញទៅរករាមនរិន្ទសមតាមបំណងនាង ហើយពេលនារីស្លូតត្រង់ចេញទៅផុតដូចជាប្រគល់ឱកាសមាសឲ្យដល់កណ្តាប់ដៃនារីមានពិសដូច្នេះដែរ។ នាងប្រញាប់ប្រញាល់ទាក់ទងទៅរកបងKenរបស់នាងភ្លាម។

-បងនៅឯណា?

សំឡេងបុរសអភិជនវិនិយោគដែកថែបតបវិញពីចុងម្ខាងដោយរីករាយ៖

-អូនសម្លាញ់សាកទាយទៅមើល៍!

លំអងញញឹមព្រោះនាយទាយដឹងពីចម្លើយហើយ។ នាងនិយាយតបវិញភ្លាម៖

-បងKenមកដល់ចាយ៉ាពូរ៉ាហើយមែនទេ?

សំឡេងបុរសនោះសើចស្រាលៗតបមកវិញជាសញ្ញាបង្ហាញថានាងទាយមិនខុសទេម្ល៉ោះហើយនារីបង្ហាញម៉ូតលំដាប់លេខ២របស់កិន្នរីហ្វេស្សិនពោលបន្តភ្លាម៖

-បងស្នាក់នៅឯណា? អូតែលណាមួយ?

-១០០ម៉ែត្រពីកន្លែងអូនឯងហ្នឹងហើយ! (អភិជនសម្បូរកលល្បិចតបវិញដោយអំនួត)

លំអងកាន់តែបានចិត្តដោយសារនាងដឹងថាគ្នីគ្នានាងបានមកដល់ក្បែរកាយហើយមានរឿងអីដែលនាងត្រូវភ័យបារម្ភពីសុវត្ថិភាពទៀតនោះ។ ប៉ុន្តែចំពោះមុខសម្តីឪម៉ាបានរំលឹកនាងឲ្យដឹងថានាង

នៅតែមិនទាន់មានលទ្ធភាពចេញទៅរកគូស្នេហ៍បានតាមចិត្តចង់ទេដោយសារថាអង្គរក្សម្នាក់ឈ្មោះរឿនដែលឪម៉ាទើបតែរំលឹកមក អាចជាបន្លាក្នុងកែវភ្នែកដ៏មុតមួយ។ នាងនិយាយតិចៗទៅកាន់Kenក្នុងកាយវិការប្រុងប្រយ័ត្នជាងមុនៈ

-បងKen! បងដឹងរឿងកូនប្រុសឧកញ៉ាឆាយាណគុណទេ? មានគេឃើញម្នាក់ហ្នឹងមកដល់ចាយ៉ាពូរ៉ាដែរ!

នាយKenហាក់មិនភ្ញាក់ផ្អើលតែបែរជារអ៊ូតិចៗៈ

-អាសិទ្ធិគុណអើយអាសិទ្ធគុណ! ថាអីចេះខុស!

-បងចង់មានន័យថាម៉េច? (លំអងសួរវិញហាក់ងឿងឆ្ងល់)

នាយKenពន្យល់ប្រាប់ស្រីស្នេហ៍ពីចុងម្ខាងនៃទូរសព្ទៈ

-សិទ្ធិគុណមកចាយ៉ាពូរ៉ា គឺបងជាអ្នកឲ្យដំណឹងគេ!

លំអងបើកភ្នែកធំៗនៅពេលត្រចៀកបន្តឮសំឡេង Kenៈ

-មិនស្មានថាវាមកដល់បានលឿនជាងដែលបងគិតទុកទៅទៀត!

នារីបង្ហាញម៉ូតពោលសួរវិញដោយមិនអស់ចិត្តៈ

-បងឯងទៅប្រាប់វាមានប្រយោជន៍អី? អ្នកមកដណ្ដើមឥន្ទបដិមាមិនឡើងដល់បីនាក់ទៅហើយបង Ken?

នាយKenសើចតិចៗរបៀបអំនួតពីចុងម្ខាងនៃទូរសព្ទៈ

-មិនមែនបន្ថែមចំនួនទេ គឺកាត់បន្ថយ!

លំអងបើកភ្នែកមូលក្រឡង់ហាក់នៅមិនទាន់យល់ ។

តាមពិតតាមរយៈឪម៉ាដែលអាចសុំនាំលំអងមកជាមួយរាមនរិន្ទ គឺជាផ្ទាក់អាចជួយឲ្យពួកគេដឹងថាកន្លែងពិតប្រាកដនៃវត្ថុមានឥន្ទបដិមា នរាធិបតិន្ទតាមពិតគឺនៅខេត្តប៉ាពួនឹងដឹងថារាមនរិន្ទកំពុងនាំគ្នាមកកាន់ចាយ៉ាពូរ៉ាក្រុងដ៏ធំរបស់ខេត្តនេះក្នុងបំណងមកឲ្យទាន់ទិវាដេញថ្លៃបដិមាដែលគេធ្លាប់តែឮតគ្នាតាមពាក្យចចាមអារ៉ាមនេះ។

ពេលនេះដំណឹងវត្ថុបុរាណបានដល់ដៃនាយKenចាំបាច់ត្រូវដើរដល់ល្បិចកលថ្មីមួយទៀតដែលធ្វើយ៉ាងណាឲ្យរតនវត្ថុនោះក្លាយជាកម្មសិទ្ធិរបស់ខ្លួនតែម្នាក់គត់ គឺកម្ចាត់រាមនរិន្ទនៅកណ្តាលផ្លូវ មុនពេលគេអាចបានតន្ទបដិមាដល់ដៃ ប៉ុន្តែដោយសារកម្លាំងទ្រព្យ និងមនុស្សរបស់រាមនរិន្ទខ្ពស់ហួសឆ្ងាយពីកម្លាំងខ្លួន នាយអភិជនដៃកថៃបចាំបាច់ត្រូវប្រើល្បិចកលថ្មី គឺលួចវាយពីទីងងឹត។

-ថាម៉េច? បងចង់ឲ្យលោកប្រុសរាមសម្លាប់កេតឌីម៉ា? (លំអងសួរវិញទាំងធ្លាក់ថ្លើមក្តុក)

នាយ Kenឆ្លើយតបមិនបង្អង់៖

-យើងត្រូវការឲ្យរាមនរិន្ទពាក់ព័ន្ធនឹងបទឧក្រិដ្ឋធំមួយដែលវាគ្មានពេលដោះខ្លួនទៅដេញថ្លៃតន្ទបដិមាបានទេ! បងរៀបចំឲ្យសិទ្ធិគុណមកគឺមានមូលហេតុពីរ ទី១អូនត្រូវធ្វើអោយរាមនរិន្ទយល់ថាសិទ្ធិគុណ និងឌីម៉ាជាបក្សពួក ហើយឌីម៉ាជាអ្នកឲ្យដំណឹងវា ពេលរាមនរិន្ទដឹងរឿងនេះ ឌីម៉ាមានជីវិត១០ក៏ពិបាករស់ដែរ!

បុរសកូនកាត់ចិនដែលមានសម្បុរសជ្រះ និងមានកេរ្តិ៍ឈ្មោះក្នុងពិភពពាណិជ្ជកម្មមានភាពកាចសាហាវជាងការគិតទុករបស់លំអងទៅទៀត។ ទោះបីមាននិស្ស័យជាមិត្តទ្រុស្តមិត្ត ប៉ុន្តែនាងក៏មិនដែលគិតថាត្រូវតែឲ្យកេតឌីម៉ាស្លាប់នោះដែរ។

លំអងនៅស្តាប់សម្តីប្រុសស្នេហ៍ទាំងញាប់ញ័រក្នុងចិត្ត។ នាងឮនាយKenបុរសគ្មានបេះដូងនិយាយបន្ថែម៖

-ទីពីរសិទ្ធិគុណមកទីនេះ ក្រៅពីធ្វើឲ្យរាមនរិន្ទជឿថាវាជាសហាយរបស់កេតឌីម៉ា គឺថែមទាំងឲ្យវាក្លាយជាសាក្សីពីការស្លាប់របស់ស្រីនោះផង! នាយចង់និយាយថា បើរាមនរិន្ទធ្វើអីកេតឌីម៉ា អ្នកដែលប្តឹងវាគឺសិទ្ធិគុណ! ចំណែកយើងនៅកន្លែងងងឹតបោសដៃចាំទទួលលាភម្នាក់ឯង!

លំអងនិយាយតបវិញដាច់ៗ៖

-តែ...តែ....យើងអត់មានមធ្យោបាយផ្សេងទេហ្អីបងKen? ហេតុអីចាំបាច់សម្លាប់ឌីម៉ា?

នាយKenនៅទ្រឹង តាមពិតគេទើបដឹងពីចំណុចខ្សោយគូកំណាន់។ តាមពិតគឺលំអងមិនដាច់ចិត្តមែន។ ប៉ុន្តែគេនៅតែចចេសពន្យល់៖

-ស្រីល្ងង់នោះអស់ការងារអីធ្វើឲ្យយើងហើយ! ដំណឹងយើងបានអស់ហើយ! កន្លែងត្រូវមក ក៏មកដល់ហើយដែរ! បំបិទមាត់នាងផង ធ្វើឲ្យរាមនរិន្ទជាប់ពិរុទ្ធផង ព្រួញមួយបាញ់បានសត្វពីរមិនល្អ?

លំអងនិយាយតបទាក់ទើរៈ

-ច្រើនណាស់បញ្ជូនវាត្រឡប់ទៅភ្នំពេញវិញទៅ! បងចាំបាច់អីសម្លាប់ឌីម៉ា?

Kenដកដង្ហើមឃ្សូរៈ

-មនុស្សស្រីនៅតែជាមនុស្សស្រីមែន! ចិត្តមិនដាច់ធ្វើស្តេចកើតដែរលំអង? ចុះធ្វើម៉េចឲ្យរាមនរិន្ទជាប់ពិរុទ្ធ? មានតែធ្វើឲ្យវាខឹងខ្លាំង ហើយចិត្តវានឹងនម្លឹងៗ បើមិនធ្វើឲ្យស្រីដែលវាស្រលាញ់ក្បត់វា វាម៉េចនឹងព្រមបញ្ចេញកំហឹង? និយាយខ្លី លំអង យើងអស់ពេលហើយសម្លាញ់ចិត្តបង! នរណាប្រើឲ្យស្រីនោះវាល្ងង់ធ្វើអី? បើថាចិត្តធម៌ណាស់ ថ្ងៃក្រោយយើងរ៉ាប់រងចិញ្ចឹមប្អូនប្រុសវាទៅ វាចប់ហើយ! ស្តាប់បងឲ្យច្បាស់ណ៎ា ស្អែកគេដេញថ្លៃរបស់នោះហើយ! បងត្រូវការឲ្យរាមនរិន្ទជាប់ពិរុទ្ធនៅថ្ងៃនេះតែម្តង ការងាររបស់អូន គឺធ្វើម៉េចឲ្យឌីម៉ាចេញមកជួបសិទ្ធិគុណ ដើម្បីឲ្យរាមនរិន្ទយល់ថានាង និងឧកញ៉ាស្ទើរភ្លើងនោះជាសហាយនឹងគ្នា ហើយសោកនាដកម្មនឹងកើតឡើង! តួប្រុសជាប់គុកដោយសារសម្លាប់តួស្រី! ចំណែកអ្នកជោគជ័យក្នុងការដេញថ្លៃ គឺយើងដែលគ្មានគូប្រជែង។

នាងលំអងឱនសម្លឹងទូរសព្ទទាំងរន្ធត់ដោយអស់ពាក្យនិយាយ។

នៅឯណេះមិត្តស្រីស្លូតត្រង់របស់នាង ក៏កំពុងវេទនាចិត្តដោយសារនាងត្រូវបង្ហាញខ្លួននៅមុខរាមនរិន្ទសាជាថ្មីហើយស្ថិតក្នុងកាលៈទេសៈដែលហាក់កាន់តែតឹងតែងទៅៗ។

កេតឌីម៉ាដើរយឺតៗកាត់តាមសួនផ្កាសាជាថ្មីសំដៅទៅអាគារម្ខាងទៀតនៃផ្ទះឈើបុរាណដែលជាទីសំណាក់របស់បុរសមានអំណាច។

នៅតាមផ្លូវនាងជួបវាក់នឹងដំណើរញាប់ស្មេររបស់នាងអង្គរក្សរឿនដែលហាក់កំពុងប្រញាប់ប្រញាល់ចាកចេញទៅធ្វើការងារសំខាន់អ្វីមួយមានកូនចៅពីរបីនាក់តាមជាប់ពីក្រោយខ្នង។ ពេលប្រទះឃើញនាងពាក់កណ្តាលផ្លូវបុរសនោះមិនត្រឹមមិនបានឱនលំទោនទេថែមទាំងងាកមុខចេញគេចពីផ្លូវនាងមិនខ្វីស្តីស្វាគមន៍អ្វី សូម្បីតែមួយម៉ាត់ធ្វើឲ្យនារីតឹងទ្រូងស្ទើរប្រេះ។

"នាយរឿន! ហេតុអ្វីយើងមិនដែលស្គាល់លោក ហើយលោកបែរជាមកស្អប់ខ្ពើមយើងដល់ថ្នាក់នេះ? ឬមួយមកពីលោកយល់ថាយើងជានារីបម្រើអារម្មណ៍គ្មានតម្លៃ ឬមួយក៏លោកដឹងថាយើងនឹងបង Kenមានកលល្បិចក្នុងការមកនៅជិតលោកប្រុសរាមរបស់លោក?"

នាងបន្តដើរហួសទៅមុខយឺតៗទាំងក្តុកក្តួលក្នុងចិត្ត។

"បងKen? តើបងកំពុងធ្វើអ្វី? បងកំពុងនៅទីណា? តើបងមានដឹងទេថាអូនកំពុងពិបាកចិត្ត? គេរកអូនទៀតហើយ មិនដឹងថាគេគិតយ៉ាងម៉េចពីអូនទេ តែអូនយល់ថាមនុស្សទាំងអស់នេះគ្មានអ្វីអាចទុកចិត្តបានឡើយ! រង់ចាំតែពេលលំអងបានលិខិតឆ្លងដែនវិញ ពេលណាអូននឹងចាកចេញទៅប្រទេសខ្មែរវិញភ្លាមមិនឲ្យពួកនេះមកឡូកឡំក្នុងជីវិតយូរទេ!"។

ភាគទី២១

តរុណីឈានមកបន្ទប់ធំនៃផ្ទះបុរាណបែបហិណ្ឌូដែលរលោងស្រិលទៅដោយការជូតសំអាតប្រេងខ្លឹមចន្ទន៍។

នៅឯសង្ហារិមឈើខ្មៅថ្លា ដែលក្រាលកល់ដោយកម្រាលព្រំពណ៌ត្នោតចាស់បុរសខ្ពស់សង្ហានៅតែរវល់ជាមួយកុំព្យូទ័ររបស់គេរហូតដល់នាងឈានដល់ពីក្រោយខ្នងមួយសន្ទុះហើយគេក៏នៅតែមិនដឹងខ្លួន។ ក្រសែភ្នែកនារីរូបល្អដែលកំពុងសម្លឹងរាមនរិន្ទពីក្រោយខ្នងមិនមែនមានន័យស្នេហា ឬចេតនាទន់ភ្លន់អ្វីទេតែនាងបែរជាងឿងឆ្ងល់ថាខ្លួនឯងមាននិស្ស័យកម្មអ្វីជាមួយបុរសនេះបានជានាងត្រូវប្រឈមនឹងគេមិនស្វាងយ៉ាងនេះ។

"រាមនរិន្ទ លោកមានលុយ និងមានអំណាច ហេតុអីលោកមិនទៅរកស្រីផ្សេងទៀតទៅ? តើលោកចាំបាច់អីមករញ៉េរញ៉ៃជាមួយជីវិតខ្ញុំ? លោកចាប់មិត្តខ្ញុំ បង្ខំខ្ញុំឲ្យមករកលោក លោកធ្វើបាបបងKen មិនឲ្យគាត់រកស៊ីបាន លោកដើរធ្វើបាបគេឯងតាមតែអំណាចគ្រួសារដែលលោកមាន ខ្ញុំមិនស្មោះត្រង់ចំពោះលោក គឺសក្តិសមហើយ បើលោកដឹងរឿងមែនក៏ខ្ញុំអត់មានអីត្រូវខ្លាចលោកដែរ មនុស្សអាក្រក់ៗដូចលោកអាចតែធ្វើបាបមនុស្សទន់ខ្សោយដែលគេគ្មានលទ្ធភាពតដៃតែប៉ុណ្ណោះ។"

កំឡាចិត្តខ្លួនឯងហើយស្រស់ស្រីឈានចូលយឺតៗទៅក្បែរគេជាមួយវាចាតិចៈ

-លោកប្រុសរាម!

បុរសអភិជនងាកក្រោយនិមិត្តឮស្រីស្រស់ពោលហៅ។ នាងសម្លឹងនាយដោយទឹកមុខញញើតញញើមព្រោះមិនដឹងថាតើអារម្មណ៍ល្អនិងអាក្រក់ទេដែលគេនឹងស្វាគមន៍មកកាន់នាង។ ប៉ុន្តែស្នាមញញឹមរបស់គេនៅតែលេចឡើងដូចសព្វមួយដងទន្ទឹមនឹងម្រាមដៃបុរសអភិជនដកចេញពីកុំព្យូទ័រ។ គេទាញបិទម៉ាស៊ីនក្នុងពេលនោះ បង្ហាញថាគេបានចុចបិទអំណាចរបស់រួចទៅហើយ។ គឺគេបានត្រៀមលក្ខណៈមុនក្នុងការឈប់ធ្វើការងារ ប៉ុន្តែតើគេនឹងធ្វើអ្វីនាង។ តើគេជឿពាក្យអង្គរក្សជំនិតដែលថានាងជាមនុស្សបង្កប់នោះដែរ ឬយ៉ាងណា?

គេញញឹមនាងក៏ចាំបាច់ត្រូវតែញញឹមតបធ្វើដូចមិនដឹងរឿង ប៉ុន្តែក្នុងចិត្តកំពុងលោតកញ្ជ្រោល។ នាងឈានចូលទៅគេក៏ក្រោកមកដែរ។ នាងឈ្ងោកមុខគេចពីពន្លឺភ្នែកគេ តែចង្កេះនាងមិនអាចគេចពីរង្វង់ដៃគេបានឡើយដូចរាល់អញ្ចឹងរាមនរិន្ទតែងតែមានស្រីស្អាតបំផុតរបស់កិន្នរីហ្វេស្សិនក្នុងរង្វង់ដៃ។ គេនិយាយដូចគ្មានអ្វីកើតឡើង៖

-ដើងនៅឈឺអត់?

កេតឌីម៉ាគ្រវីក្បាលតិចៗធ្វើឲ្យរាមនរិន្ទញញឹម។ នរៈនិយាយបន្ថែម៖

-ចេញទៅដើរលេងទេ?

តរុណីដកដង្ហើមយូរធូរពីភាពតឹងតែង នាងញញឹមជាសញ្ញាមិនបដិសេធ ប៉ុន្តែតាមពិតគឺមកពីនាងគ្មានជម្រើស។

-ចាយ៉ាពូរ៉ាមានកន្លែងដើរច្រើនណាស់! យើងដើរមើលទៅ? (គេនិយាយបន្ថែម)

តរុណីងើបមុខសម្លឹងគេ។ ពន្លឺភ្នែកគេនៅតែស្រទន់ ប្រសិនបើមិនបានមើលឃើញផ្ទាល់ភ្នែកនាងមុខតែមិនអាចស្មានបានទេថាមុននេះគេទើបតែបានទទួលសេចក្តីរាយការណ៍ដ៏គ្រោតគ្រាតពីមនុស្សជំនិតនោះ។

នាងក្រមុំរូបល្អឆ្លើយតបវិញ៖

-ចាំ!

រាមនរិន្ទ និងកញ្ញាស្រស់ស្អាតបានចាកចេញពីផ្ទះបុរាណ។ នារីបង្ហាញម៉ូតហាក់បានធូរចិត្តដោយសារនាងនៅជាមួយបុរសមានអំណាចតែពីរនាក់មិនមានវត្តមានបុរសអង្គរក្សឈ្មោះរឿនដ៏គ្រោតគ្រាតនោះ។

តាក់ស៊ីបានឈប់នៅតំបន់មួយស្ងប់ស្ងាត់តែប្រកបដោយទេសភាពស្រស់ត្រកាល។ជំនោរត្រជាក់និងបរិសុទ្ធគ្មានចំហាយកាកសំណល់ឧស្សាហកម្មបានបបោសអង្អែលស្បែកពណ៌ទឹកឃ្មុំហ្មត់ល្វត់របស់នាងតាំងពីស្រីស្រស់ឈានជើងចុះពីជំនិះម្ល៉េះ។ បុរសអភិជនបានឲ្យតាក់ស៊ីចាកចេញទៅប្រហែលជាគេចង់ចំណាយពេលជាមួយធីតារូបល្អតែម្នាក់ឯងក៏មិនដឹង?

-ឌីម៉ា! នេះគឺស្ទឹងSentani !

គេដឹកដៃនាងចុះយឺតៗតាមជម្រាលស្មៅបៃតងត្រកាលក្រាលលាតសន្ធឹងឡោមព័ទ្ធស្ទឹងសេនតានីដ៏ល្អប្រណិតរបស់ក្រុងចាយ៉ាពូរ៉ា។ ជាតិបរិសុទ្ធនៃធម្មជាតិបានសណ្តំនារីប្រែកបដោយទុក្ខព្រួយឲ្យត្រេកត្រអាលមួយគ្រាសាជាថ្មី។ នាងញញឹមទៅរកហ្វូងបក្សីបក្សាដែលច្រវាត់ហោះហើរកៀងគ្នាប៉ប្រះមាត់ទឹក។ សរសៃសក់ទន់ល្មើយហើរមកប៉ះនាសានរះអភិជនដែលកំពុងគយគន់ធ្មេញសត្រឹមដូចផ្កាម្លិះរបស់នារីក្បែរកាយ។

"កេតឌីម៉ា នាងសើចស្អាតយ៉ាងនេះ ម៉េចក៏ពីមុនមកមិនដែលឃើញនាងសើចសោះ?"រាមនរិន្ទនឹកក្នុងចិត្តស្ងាត់ៗម្នាក់ឯងក្នុងពេលក្រសែភ្នែកនាយកំពុងត្រូវសម្រស់ស្រីល្អអន្ទងយកទៅ។

រាមនរិន្ទជាកម្លោះរូបស្អាតជាមនុស្សមានឥទ្ធិពល មិនខ្វះទេនារីដែលប្រាថ្នាក្លាយជាទីចាប់អារម្មណ៍របស់គេ តែហេតុអ្វីបានជាឌីម៉ាស្ថិតនៅក្នុងរង្វង់ដៃគេពេលណានាង បែរជាមានអារម្មណ៍ទើសទាល់? នេះក៏ព្រោះតែនាងដឹងថា ចំពោះមុខប្រុសម្នាក់នេះ នាងគ្រាន់តែជាល្បែងម្យ៉ាងដែលគេទិញមកដោយប្រាក់ គេឈប់ត្រូវការនាងដោយបំភ្លេចនាងចោលតាំងពីដណ្តើមបានភាពបរិសុទ្ធនាថ្ងៃដំបូងម្ល៉េះ តែថ្ងៃនេះគេលេងសើចជាមួយនាងសារជាថ្មីព្រោះតែចង់សម្តែងឫទ្ធិឲ្យមនុស្សគ្រប់គ្នាដឹងថា អ្វីដែលគេឯងយកមិនបាន អភិជនសិទ្ធិគុណយកមិនបានរាមនរិន្ទគឺអាចយកបានដោយងាយ។ ...

ក្នុងចិត្តរាមនរិន្ទឯណោះវិញ គេចាប់ផ្តើមមានអារម្មណ៍ប្លែកជាមួយឌីម៉ា។ បេះដូងដែលមិនធ្លាប់ចុះចាញ់ក្រោមសម្រស់នារីណាម្នាក់ហាក់បីដូចជាលេចចេញនូវសញ្ញាសម្ងាត់មកថាគេចង់ដឹងពីនារីម្នាក់នេះថានាងសំអាងលើអ្វី បានជាប្រកាន់ឫកពាប្លែកពីនារីផ្សេងៗម្ល៉េះ? និយាយតិចតែចិត្តរឹងមិនខ្លាចសូម្បីតែការគំរាមរបស់សិទ្ធិគុណមិនព្រមម៉្មិកម៉្ញក់យកចិត្តរាមនរិន្ទខុសប្លែកពីនារីច្រើនដែលគេធ្លាប់ជួប។...

មិនខុសទេរាមនរិន្ទ ជាស្រទាប់យុវវ័យដែលចូលចិត្តសាកល្បងល្បែងស្នេហ៍ជាមួយស្រីស្អាតអាចនិយាយថាមាននារីច្រើនហើយដែលចូលមកក្បែរគេដើម្បីប្រជែងជាមនុស្សសំខាន់ក្នុងជីវិតបុរសមានទាំងប្រាក់មានទាំងអំណាច...តែក្រោយការសេពគប់គ្នា បុរសដែលចាប់កំណើតលើវិថីក្រាលដោយភាពរុងរោចន៍ទទួលស្គាល់ថាពិតជាពិបាករកបាននរណាម្នាក់ដែលស្រលាញ់នាយពិតណាស់ រហូតដល់នាយគិតថាស្នេហាមិនមែនជាជម្រើសទី១របស់ខ្លួនដូចយុវវ័យឯទៀតទេ។

អ្នកស្រីកូឡាបនាំកេតឌីម៉ាទៅឲ្យរាមនរិន្ទប៉ុន្តែគាត់ដឹងប្រាកដណាស់ថានាងក៏មានវាសនាមិនខុសពីស្រីមុនៗដែរ ព្រោះរាមនរិន្ទមិនដែលនឹកនាដល់ជាលើកទី២ទៀតទេ អញ្ចឹងហើយបានមកដល់កោះឥណ្ឌូណេស៊ីភ្លាមគាត់ហ៊ានបញ្ចុះបញ្ចូលឌីម៉ាឲ្យទៅសិទ្ធិគុណ ដើម្បីលាភសក្ការៈ ។...

ប៉ុន្តែហេតុការណ៍នេះដែរបានជួយអោយនារីរូបស្រស់ ដែលមិនធ្លាប់មានស្រមោលបន្សល់បន្តិចណាក្នុងប្រអប់បេះដូងរឹងដូចដែកថែបនៃកំលោះអភិជនសោះនេះផ្លាស់ប្តូររូបភាពក្នុងគំនិតគេត្រឹមពេលដែលរាមនរិន្ទមើលឃើញផ្ទាល់ភ្នែកថានាងមិនមែនជានារីដែលអាចអូសទាញបានដោយសម្ភារៈនោះឡើយ។

គេពោលសួរនាងតិចៗដោយសម្លឹងទៅ តរុណី ដែលកំពុងលង់ទៅក្នុងភាពទាក់ទាញរបស់ធម្មជាតិ ៖

- លំអងយ៉ាងម៉េចហើយ ?

នាងស្វាងចេញពីភាពត្រេកត្រអាលដោយដឹងថានៅក្បែរ ខ្លួនកំពុងមានមនុស្សគួរអោយទើសទាល់ម្នាក់។នាងនិយាយតប៖

- អត់អីទេ! លែងសូវកើតទុក្ខហើយ! តែក៏កំពុងរង់ចាំអោយឆាប់បានលិខិតឆ្លងដែននឹងអាលត្រឡប់ទៅវិញលែងរំខានលោកប្រុសទៀត!

បុរសរូបសង្ហាលាដៃក្រសោបនារីតូចស្តើងពីក្រោយ។ គេនិយាយតិចៗ៖

- ចុះឌីម៉ានៅទីនេះបន្តទៀតកុំទាន់ត្រឡប់ទៅភ្នំពេញវិញបានទេ?

ឌីម៉ាបើកភ្នែកធំៗដោយក្តីភ្ញាក់ផ្អើល។ នាងងាកសម្លឹងទៅរាមនរិន្ទ ដែលនៅក្បែរខ្លួនបង្អើយ ទឹកមុខគេដែលញញឹមដាក់មាណវីនៅតែបង្កប់មកនូវអំណាចម្យ៉ាងដែលបង្ហាញយ៉ាងច្បាស់ថាគេមិនមែននិយាយលេងទេ។ ធីតាយើងខំប្រឹងតបវិញ ៖

- តែ... ខ្ញុំ...

រាមនរិន្ទក្រសោបរាងកាយតូចតន់ណែនជាងមុនហាក់ខ្លាចរបេះបាត់៖

- តែ... យ៉ាងម៉េច ?...

ឃើញកែវភ្នែកមុតថ្លាទាំងគូរសម្លឹងមកខ្លួន នាងក៏រកនិយាយអ្វីក៏លែងចេញហើយដែរ នាងទទួលស្គាល់ថាខ្លួនមានអារម្មណ៍ចុះចាញ់គេជានិច្ច បានត្រឹមបើកភ្នែកភ្លឹះៗសម្លឹងគេ និងរង់ចាំស្តាប់គេ

និយាយប៉ុណ្ណោះ។ នរិន្ទញញឹម លើកម្រាមអង្អែលផែនថ្កាល់រលោងដូចផ្លែទន្លាប់ ដែលស្ថិតនៅចំពីមុខខ្លួន មាត់ពោលបន្ត ៖

-ខ្ញុំមានការងារខ្លះទៀតត្រូវធ្វើនៅទីនេះ... ឪម៉ានៅទីនេះដែរចាំទៅវិញជាមួយគ្នាណ៎ា?

ស្ថានភាពមួយយ៉ាងស្មុគស្មាញអណ្តែតមកលើផ្ទៃមុខធីតាបង្ហាញម៉ូត នាងវាចាតិចៗទៅកាន់គេវិញ ៖

- លោកប្រុសរាម !... មិនបានទេ !

រាមនរិន្ទ សើចស្រស់ឱនមកខ្សឹបក្បែរត្រចៀកកល្យាណី៖

- បើយើងមានចិត្តដូចគ្នា ម៉េចមានពាក្យថា"មិនបាន"ទៅ? លើកលែងយើងមានខ្លួននៅកន្លែងនេះ ចិត្តនៅកន្លែងផ្សេង?

ម្តងណោះឪម៉ាសម្លឹងមុខរាមនរិន្ទ មិនដាក់ភ្នែកតែម្តង។ នាងចង់ដឹងថាតើគេនិយាយនេះមានន័យដូចម្តេចរឺមួយគេ យល់ស្របតាម ការសន្និដ្ឋានរបស់អង្គរក្សរឿនដែលថា នាងជាមនុស្សបង្កប់របស់សិទ្ធិគុណ?

-យ៉ាងម៉េច? បារម្ភពីប្អូនអ្ហេស៎? ខ្ញុំនឹងចាត់ឲ្យមនុស្សទៅមើលថែជំនួស!ព្រោះយើងប្រហែលជានឹងត្រូវនៅទីនេះយូរ !...

ស្រស់ស្រីហាក់ចង់ឲ្យប្រុសម្នាក់នេះ យល់ពីការលំបាករបស់ខ្លួនណាស់...ទើបនាងខំប្រឹងវាចាទៅកាន់គេ ៖

- តែ... ក្រុមការងារ... គេមិនអនុញ្ញាតឲ្យខ្ញុំធ្វើអញ្ចឹងទេ... !

រាមនរិន្ទ សម្លឹងមុខស្រស់ស្រីយ៉ាងមុត ហាក់ចង់មើលឲ្យធ្លុះថា ហេតុអ្វីបានជានាងបដិសេធសំណើរបស់ខ្លួនម្តងជាពីរដងបែបនេះ? វាមិនដែលថាខ្លួនមានចេតនាល្អចំពោះនាងដាក់ខ្លួនដាក់កាយជាមួយនាងដល់ថ្នាក់នេះ នាងបែរជាមិនមានសន្តានចិត្តតបស្នងសូម្បីតែបន្តិចថានាងមានមនោសញ្ចេតនាមកឲ្យខ្លួនវិញសោះ។ ឬមួយថាការដែលនាងខំធ្វើទាំងឡាយកន្លងមកសុទ្ធតែដើម្បីការពារស្រ្តីមេអណ្តើក និងមិត្តនារីរបស់នាងទេ?

ចិត្តមានៈលេចឡើងតាមធម្មជាតិនៃបុរសត្រកូលខ្ពស់ដែលកម្រមានគេហ៊ានជំទាស់ចិត្ត។គេចង់បញ្ចេញភាពម្ចាស់ហ្មងឲ្យនាងដឹងខ្លួនម្តងដែរថាកុំឲ្យបានចិត្តពេកតែពេលគេប្រទះឃើញសេចក្តីព្រួយ

បារម្ភពិតៗឥតក្លែងក្លាយផុសចេញពីកែវភ្នែកល្អល្អះទាំងគូរនៃអ្នកគ្រូវ័យក្មេង... គេទប់កំហឹង... ពោលសួរនាងសាជាថ្មី ៖

- អ្នកណាជាអ្នកគ្រប់គ្រងក្លឹបបង្ហាញម៉ូត !... ចាំខ្ញុំឲ្យមនុស្សទៅនិយាយជាមួយគេ !...

កេតុឪម៉ាហួសចិត្ត... នាងនៅស្ងៀមងាកមុខចេញលែងតប...ព្រោះភាពតានតឹងកំពុងច្រាលពីទ្រូងមកណែនត្រង់បំពង់កទាំងមូលទៅហើយ។

រាមនរិន្ទ ញញឹមបន្លឺបន្ត ៖

- យល់ព្រមណ៎ា !... ខ្ញុំនឹងឲ្យមនុស្សទៅដោះស្រាយជាមួយប្រធានក្លឹបរបស់នាង!...

គេលូករកទូរស័ព្ទតែមិនទាន់បានចុចផងឪម៉ាហើបមាត់ឃាត់ដោយច្រាស់ច្រាល់ ៖

- លោកចង់ឲ្យមនុស្សប៉ុន្មាននាក់ទៀតដឹងរឿងនេះ ! ? ?

សូរសព្ទដែលលាយឡំទាំងភាពរអាក់រអួល ព្រមជាមួយអត្ថន័យបន្ទោសខឹងសម្បារនេះ បានបណ្ដាលឲ្យរាមនរិន្ទ ទុចម្រាមដៃងាកមករកស្រស់ស្រីវិញភ្លាម... ។.. គេខិនមើលម្រាមដៃនាងដែលតោងហត្ថខ្លួនជាប់ក្នុងបំណងឃាត់មិនឲ្យខ្លួនប្រើឧបករណ៍បញ្ជូនសំឡេងទៅបង្គាប់កូនចៅឲ្យធ្វើតាមអ្វីដែលខ្លួនទើបតែបង្ហើបអម្បាញ់មិញ។ ទឹកមុខដែលមិនអាចលាក់បាំងបាននូវភាពឈឺចាប់របស់តរុណី បានធ្វើឲ្យរាមនរិន្ទមួហ្មង... គេប្រែទឹកមុខទៅជាស្មើធេង...គេចង់ពោលសួរនាងថា... យល់ថាថោកទាបណាស់ទៅ ឬ ដែលរស់នៅក្បែរ រាមនរិន្ទ... តែ.. គេបែរជាទប់ចិត្ត ពេលដែលឃើញឪម៉ាឈ្ងោកមុខយំសស្រាក់។

ទឹកភ្នែកនាងធ្វើអោយនរិន្ទទទួលស្គាល់ថា កាលបើមនុស្សស្រីម្នាក់នេះព្យាយាមការពារកិត្តិយសរបស់ខ្លួន...មិនគួរក្លាយទៅជារឿងត្រូវខឹងសម្បារនឹងនាងឡើយ...អញ្ចឹងហើយបានជាកំលោះអភិជនរូបនេះ សង្កត់ចិត្តឲ្យត្រជាក់វិញ ដោយពោលទៅរកនាងតាមសម្រួល...

- បើមិនចង់ឲ្យគេដឹង !... អញ្ចឹងឈប់ធ្វើការទៅ !... ក្លឹបនោះឲ្យចំណូលនាងប៉ុន្មាន... ខ្ញុំរ៉ាប់រងទាំងអស់ !...

កេតុឪម៉ាងាកមុខចេញ... នាងកំពុងពិចារណាទាំងមួហ្មង... អ្នកមានប្រាក់ហារមួយម៉ាត់ណា ក៏យកលុយដាក់ពីមុខដោយមិនរវល់ពីអារម្មណ៍អ្នកណាឡើយ... តែនាងក៏ដឹងដែរថា... នាងគ្មានមធ្យោបាយគេចចេញគំនាបនេះទេ... ព្រោះនាងជាកូនបំណុល។..

តែនៅម្ខាង ណេះវិញរាមនរិន្ទ ដឹងប្រាកដថា... ចិត្តខ្លួនបែរទៅជាទន់ជ្រាយយ៉ាងរហ័សចំពោះមុខស្រីម្នាក់ ដែលមុននេះ មិនធ្លាប់មានថ្ងៃណា ដែលនឹកនាដល់នាងបន្តិចណាសោះ។ បើថាព្រោះតែរូបសម្ផស្សនោះក៏មិនមែន... ថាព្រោះតែអ្នកស្រណោះដល់រាត្រីដំបូងជាមួយនាងក៏មិនត្រូវ... តែបើសំអាងលើឫកពាប្លែករបស់ឌីម៉ាប្រហែលត្រូវជាង ព្រោះកន្លងមកគេមិនធ្លាប់ជួបនារីណាដែលមានអត្តចរិតបែបនេះចំពោះមុខខ្លួនទេ ...។

គេសម្លឹងផែនថ្ពាល់ដែលបន្សល់នូវដំណក់ទឹកភ្នែកថ្លាឆ្វង់នៅឡើយ...ដោយប្រឹងញញឹមទាំងលូកដៃក្រសោបរាងកាយតូចច្រឡឹងពេញក្នុងរង្វង់ដៃសារជាថ្មី... គេពោលស្រាលៗទៅកាន់នាង ៖

- បើព្រមនៅទីនេះជាមួយគ្នាតាំងពីដំបូង អត់មានរឿងត្រូវវែងឆ្ងាយអញ្ចឹងទេ. !...

នៅពេលដែលនារីស្លូតត្រង់កំពុងស្ថិតក្នុងស្ថានភាពចុះទឹកក្រពើឡើងលើខ្លានៅឯណេះ លំអងក៏កំពុងច្រាស់ច្រាល។

នាងក៏ស្ថិតនៅពាក់កណ្តាលការសម្រេចចិត្តថាតើអាចធ្វើយ៉ាងណាឲ្យសង្គ្រាសំណព្វសម្រេចបានគម្រោងការ ប៉ុន្តែក៏មិនឲ្យកេតុឌីម៉ាស្លាប់។ តាមផែនការរបស់Kenគេចង់ឲ្យលំអងទៅរករាមនរិន្ទហើយសារភាពថាខ្លួនមិនបាត់លិខិតឆ្លងដែនអ្វីទាំងអស់ដោយបង្វែរថាខ្លួនធ្វើតាមឌីម៉ាដែលងប់ស្រលាញ់សិទ្ធិគុណហើយរកល្បិចនេះដើម្បីបានមកចាយ៉ាពូរ៉ាតាមរានរិន្ទ និងលួចរាយការណ៍ទៅប្រាប់សិទ្ធិគុណឲ្យដឹងពីដំណើរនេះជាលទ្ធផលសិទ្ធិគុណបានមកដល់ទីនេះមែន។

Kenដឹងទៀតថាការនិយាយតែមាត់មិនអាចឲ្យរាមនរិន្ទមានកំហឹងលើកេតឌីម៉ាបានឡើយ ប៉ុន្តែបើធ្វើឲ្យគេឃើញផ្ទាល់ភ្នែកទើបអាចទៅរួច ម្ល៉ោះហើយជំហានបន្ទាប់គឺគេឲ្យលំអងបញ្ឆោតកេតុឌីម៉ាអោយចេញទៅរកសិទ្ធិគុណ។

ប៉ុន្តែចំណុចសំខាន់បំផុតគឺនាងនៅមិនដាច់អាល័យពីមិត្តដ៏ត្រង់ និងឆោតរបស់ខ្លួន។

"កេតឌីម៉ា ទោះបីឯងជាសត្រូវស្នេហារបស់យើង ឯងជាសត្រូវអាជីព និងមានអ្វីៗដែលយើងត្រូវច្រណែននិងទើសភ្នែក តែយើងក៏នៅតែមិនដាច់ចិត្តឲ្យឯងស្លាប់។ ព្រោះថាអំពើល្អនិងសន្តានចិត្តស្មោះដែលឯងមានចំពោះយើងកន្លងមកនៅតែអាចធ្វើឲ្យមនុស្សអាក្រក់ដូចយើងរំភើបបាន។ បើយើងដណ្តើមបងKenពីឯងបានទៅហើយ ចាំបាច់អីយើងត្រូវអាក្រក់មួយត្រួតទៀតផ្តាច់ជីវិតឯងនោះ! ហោចណាស់ក៏យើងនៅតែចង់បានឯងជាមិត្ត ទោះបីយើងមានគោលដៅមិនស្របគ្នាក៏ដោ

យ។ យើងមានតែរកវិធីមួយធ្វើយ៉ាងណាឲ្យរាមនរិន្ទនៅតែជាប់ពិរុទ្ធដើម្បីបងKenបានឱកាសយកតន្ទបដិមា តែអ្នកដែលរាមនរិន្ទសម្លាប់មិនមែនឯងទេគឺសិទ្ធគុណ"។

នារីដ៏វៃឆ្លាតបានប្រើបញ្ញាដោះស្រាយស្ថានការណ៍ដ៏ស្មុគស្មាញនេះតាមរយៈការប្រើមធ្យោបាយចាស់របស់នាយKenក្នុងការដុតកំហឹងរាមនរិន្ទដោយលើកឡើងពីទំនាក់ទំនងឌីម៉ា និងសិទ្ធិគុណថានាងជារនុកក្នុង ប៉ុន្តែនាងការពារជីវិតឌីម៉ាដោយកែប្រែមួយចំណុចទៀតថានាងធ្វើនេះព្រោះតែឆោតល្ងង់និងចាញ់បោកសិទ្ធិគុណដើម្បីឲ្យរាមនរិន្ទបង្វែរកំហឹងទាំងស្រុងទៅបុរសក្មេងកូនកាត់ខ្មែរថៃនោះហើយទីបំផុតគេនឹងបញ្ចេញកំហឹងដែលធ្វើឲ្យគេនៅតែជាប់ពិរុទ្ធគ្មានពេលទៅចូលរួមដេញថ្លៃឡើយ។

"កេតុឌីម៉ា! ខ្ញុំបានធ្វើរឿងមួយជួយឯង! ចាត់ទុកថាយើងរួចគ្នាចុះ! លើកនេះបើរាមនរិន្ទពិតជាស្រលាញ់ឯង គេមុខតែអត់ទោសឲ្យឯងចំពោះការចាញ់បោកសិទ្ធិគុណ ហើយអ្នកត្រូវថ្មោងមែនទែនគឺសិទ្ធិគុណមិនមែនឯងទេ! តែបើរាមនរិន្ទអត់មានចិត្តទន់ គេខឹងហើយសុខចិត្តលះបង់ទាំងឯងទៀតនោះ នេះជាវាសនារបស់ឯងទេ! កុំបន្ទោសយើង!"។

តើរាមនរិន្ទនឹងលុះក្រោមកលល្បិចរបស់អភិជនKenដែរទេ?

គេអាចនឹងធ្វើបាបតួឯកស្រីរបស់គេ ឬសិទ្ធិគុណឲ្យខ្លួនជាប់ពិរុទ្ធមែនឬយ៉ាងណា?